ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីណែនាំប្រតិបត្តិ

## ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ឆ្នាំ ២០២១

# បុព្វកថា

កិច្ចប្រឹងប្រែងធ្វើកំណែទម្រង់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ របស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើឱ្យវិស័យអប់រំនៅកម្ពុជាមានការរីកចម្រើន និងការប្រែប្រួលគួរឱ្យកត់សម្គាល់។ វឌ្ឍនភាពនេះ បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងប្រត្យក្ស ពីការយកចិត្តទុកដាក់ខ្ពស់របស់ក្រសួងក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក៏ដូចជាបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។ ក្រសួងបានចាត់ទុកគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំដទៃទៀត ជាធនធានអាទិភាព និងជាកម្លាំង ចលករស្នូលមិនអាចខ្វះបានក្នុងការអភិវឌ្ឍមូលធនមនុស្ស សម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិប្រកបដោយចីរភាព។ ក្នុងន័យនេះ ក្រសួង បានរៀបចំក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ដើម្បី ទាក់ទាញ រក្សា គាំទ្រ លើកកម្ពស់ និងលើកទឹកចិត្តបុគ្គលិកអប់រំដែលមានគុណសម្បត្តិល្អៗ ឱ្យបន្តបម្រើការងារប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រព័ន្ធអប់រំ។

ដើម្បីជានាឱ្យមានភាពងាយស្រួល ច្បាស់លាស់ និងប្រសិទ្ធភាពក្នុងការអនុវត្តក្របខណ្ឌនេះ ក្រសួង បានរៀបចំសេចក្តីណែនាំប្រតិបត្តិក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន សម្រាប់ជាមគ្គុទ្ទេសក៍ បង្ហាញផ្លូវអ្នកអនុវត្តនៅគ្រប់កម្រិត។ ឯកសារនេះ រៀបរាប់ និងពន្យល់លម្អិតពីរបៀបនៃការអនុវត្ត ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន រួមមាន ការកំណត់ឋានៈវិជ្ជាជីវៈតាមគន្លងអាជីពនីមួយៗ លក្ខណៈវិនិច្ឆ័យការវាយតម្លៃ ប្រព័ន្ធលើកទឹកចិត្ត និងការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងចំណុចពាក់ព័ន្ធផ្សេងៗទៀត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយជាផែនទីបង្ហាញផ្លូវដ៏សំខាន់សម្រាប់គ្រប់ភាគីពាក់ព័ន្ធយកទៅអនុវត្តប្រកបដោយជោគជ័យ។

ថ្ងៃ សុក្រ ១ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការរៀបចំ និងត្រួតពិនិត្យឯកសារ

## ក. គណៈកម្មការគ្រប់គ្រង និងដឹកនាំ

| | | | | |
|---|---|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន** | **ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត** | **ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. ឯកឧត្តម | **លឹម** | **សុជា** | អគ្គនាយក អ.គ.ផ | សមាជិក |
| ៤. ឯកឧត្តម | **ពុត** | **សាមិត្ត** | អគ្គនាយក អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៥. លោកបណ្ឌិត | **ឌី** | **សមស៊ីដេត** | អគ្គនាយករង អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៦. ឯកឧត្តមបណ្ឌិត | **ឌី** | **ខាំបូលី** | អគ្គនាយករង អ.គ.ផ | សមាជិក |
| ៧. ឯកឧត្តម | **នៀ** | **សុផន** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៨. ឯកឧត្តម | **ស៊ិន** | **សេងហុក** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៩. លោកស្រីបណ្ឌិត | **បូ** | **ច័ន្ទគុលិកា** | ប្រធាននាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០. លោក | **ព្រីង** | **មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | សមាជិក |

## ខ. គណៈកម្មការបច្ចេកទេស និងចងក្រង

| | | | |
|---|---|---|---|
| ១. លោកបណ្ឌិត | **ឌី** | **សមស៊ីដេត** | អគ្គនាយករង អគ្គនាយកដ្ឋានអប់រំ |
| ២. ឯកឧត្តមបណ្ឌិត | **ឌី** | **ខាំបូលី** | អគ្គនាយករង អគ្គ.គោលនយោបាយ និងផែនការ |
| ៣. លោកស្រីបណ្ឌិត | **បូ** | **ច័ន្ទគុលិកា** | ប្រធាននាយកដ្ឋានគោលនយោបាយ |
| ៤. លោក | **នៅ** | **សៅវរៈ** | អនុប្រធាននាយកដ្ឋានគោលនយោបាយ |
| ៥. លោក | **ញាណ** | **ប៊ុនរិទ្ធ** | អនុប្រធាននាយកដ្ឋានបុគ្គលិក |
| ៦. លោក | **លី** | **គាង** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៧. លោក | **មាឃ** | **ចាន់ថេង** | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| ៨. លោក | **យុត** | **សុខា** | ប្រធានការិយាល័យ នាយកដ្ឋានគោលនយោបាយ |
| ៩. លោកស្រី | **អ៊ុន** | **ស្រីណែត** | អនុប្រធានការិយាល័យ នាយកដ្ឋានគោលនយោបាយ |
| ១០. លោក | **សំ** | **សែន** | អនុប្រធានការិយាល័យនាយកដ្ឋាននីតិកម្ម |
| ១១. លោក | **ជ័យ** | **រដ្ឋា** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ១២. លោក | **មត** | **សុមឿន** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ១៣. លោក | **ខាត់** | **សុភ័ស្ត** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ១៤. កញ្ញា | **ឆាយ** | **វួចអ៊ីម** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ១៥. លោក | **អែម** | **ណាឃីម** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ១៦. លោក | **នួម** | **សុខុន** | មន្ត្រីអង្គការ UNICEF |
| ១៧. លោក | **ខាន់** | **បូផាន់** | មន្ត្រីអង្គការ UNESCO |

## គ. គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

| | | | |
|---|---|---|---|
| ១. លោក | **ខាត់** | **សុភ័ស្ត** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ២. កញ្ញា | **ឆាយ** | **វួចអ៊ីម** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |
| ៣. លោក | **អែម** | **ណាឃីម** | មន្ត្រី នាយកដ្ឋានគោលនយោបាយ |

# មាតិកា


១. សេចក្តីផ្តើម ........................................ ១

២. គន្លងអាជីពគ្រូបង្រៀន ........................................ ១

២.១. គន្លងបង្រៀន ........................................ ១

២.២. គន្លងគ្រប់គ្រង ........................................ ២

២.៣. គន្លងឯកទេសអប់រំ ........................................ ៣

២.៤. ការឆ្លងគន្លង ........................................ ៤

២.៥. គន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ........................................ ៤

៣. លក្ខណៈវិនិច្ឆ័យ ........................................ ៤

៣.១. លក្ខណៈវិនិច្ឆ័យសម្រាប់គន្លងបង្រៀន ........................................ ៥

៣.២. លក្ខណៈវិនិច្ឆ័យសម្រាប់គន្លងគ្រប់គ្រង ........................................ ៣៨

៣.៣. លក្ខណៈវិនិច្ឆ័យសម្រាប់គន្លងឯកទេសអប់រំ ........................................ ៦៩

៣.៣.១. ឯកទេសគោលនយោបាយ និងផែនការអប់រំ ........................................ ៧០

៣.៣.២. ឯកទេសអភិវឌ្ឍន៍កម្មវិធីសិក្សា ........................................ ៧៩

៣.៣.៣. ឯកទេសការវាយតម្លៃលទ្ធផលសិក្សា ........................................ ៩២

៣.៣.៤. ឯកទេសគរុកោសល្យ និងវិធីសាស្ត្របង្រៀន ........................................ ១០៥

៣.៣.៥. ឯកទេសគ្រប់គ្រងរដ្ឋបាលអប់រំ ........................................ ១១៥

៤. ប្រព័ន្ធវាយតម្លៃ ........................................ ១២៤

៤.១. ការវាយតម្លៃ ........................................ ១២៤

៤.១.១. កម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា ........................................ ១២៦

៤.១.២. កម្រិតជាតិ ........................................ ១៣៩

៤.២. ការដាក់ពិន្ទុ ........................................ ១៤៤

**៤.៣. ការកត់ត្រាព័ត៌មាន** ........ ១៤៦

**សន្ទានុក្រម** ........ ១៤៧

**ឧបសម្ព័ន្ធ** ........ ១៥១

ឧបសម្ព័ន្ធ ១៖ ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ ........ ១៥១

ឧបសម្ព័ន្ធ ២៖ ទម្រង់ពិនិត្យវឌ្ឍនភាពពាក់កណ្ដាលឆ្នាំ ........ ១៥៣

ឧបសម្ព័ន្ធ ៣៖ ឧបករណ៍វាយតម្លៃការងារចុងឆ្នាំ ........ ១៥៥

ឧបសម្ព័ន្ធ៤៖ ឧបករណ៍ស្វ័យវាយតម្លៃការងារប្រចាំឆ្នាំ ........ ១៥៧

ឧបសម្ព័ន្ធ ៥៖ ឧបករណ៍ប្រមូលព័ត៌មាន ៣៦០ ដឺក្រេ ........ ១៥៩

ឧបសម្ព័ន្ធ ៦៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងបង្រៀន ........ ១៦១

ឧបសម្ព័ន្ធ ៧៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងគ្រប់គ្រង ........ ១៧៦

ឧបសម្ព័ន្ធ៨៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងឯកទេសអប់រំ (អភិវឌ្ឍគោលនយោបាយនិងផែនការអប់រំ) ........ ១៨៧

ឧបសម្ព័ន្ធ៩៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងឯកទេសអប់រំ (អភិវឌ្ឍកម្មវិធីសិក្សា)..១៩៣

ឧបសម្ព័ន្ធ១០៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងឯកទេសអប់រំ (វាយតម្លៃលទ្ធផលសិក្សា) ........ ២០១

ឧបសម្ព័ន១១៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងឯកទេសអប់រំ (គរុកោសល្យនិងវិធីសាស្ត្របង្រៀន) ........ ២១០

ឧបសម្ព័ន១២៖ ឧបករណ៍វាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន គន្លងឯកទេសអប់រំ (គ្រប់គ្រងរដ្ឋបាលអប់រំ) ........ ២១៦

## ១. សេចក្តីផ្តើម

គ្រូបង្រៀន ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យគុណភាពអប់រំប្រសើរឡើង ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិ។ ដោយមើលឃើញពីសារៈសំខាន់នេះហើយ ទើបបណ្តាប្រទេសមួយចំនួនក្នុងពិភពលោកបានរៀបចំគោលនយោបាយឬក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។ ក្របខណ្ឌនេះ ជាយន្តការលើកទឹកចិត្តនិងផ្តល់គុណតម្លៃដល់បុគ្គលិកអប់រំដែលមានគុណសម្បត្តិ និងឧបនិស្ស័យឱ្យបន្តបម្រើការងារនៅក្នុងវិស័យអប់រំបានយូរ។

ឆ្លើយតបនឹងនិន្នាការខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ក្នុងគោលបំណងទាក់ទាញ រក្សា គាំទ្រ លើកទឹកចិត្ត និងផ្តល់គុណតម្លៃដល់បុគ្គលិកដែលមានឧបនិស្ស័យ និងទេពកោសល្យក្នុងវិស័យអប់រំ។ ក្របខណ្ឌនេះ រៀបចំឡើងដោយផ្អែកលើភស្តុតាងនិន្នាការ និងបទពិសោធរបស់បណ្តាប្រទេសអភិវឌ្ឍន៍ក្នុងតំបន់និងសកលលោក ដើម្បីឆ្លើយតបទៅនឹងតម្រូវការសង្គម សេដ្ឋកិច្ចជាតិ អន្តរជាតិ និងដោះស្រាយបញ្ហាសំខាន់ៗនានាក្នុងវិស័យអប់រំ។

ក្រសួង រៀបចំសេចក្តីណែនាំប្រតិបត្តិនេះ សម្រាប់ជាផែនទីបង្ហាញផ្លូវដល់អ្នកអនុវត្តនៅគ្រប់កម្រិត។ សេចក្តីណែនាំប្រតិបត្តិ រៀបរាប់ និងពន្យល់លម្អិតពីចំណុចសំខាន់ៗដែលត្រូវអនុវត្ត រួមមានការកំណត់ឋានៈវិជ្ជាជីវៈតាមគន្លងអាជីពនីមួយៗ លក្ខណៈវិនិច្ឆ័យ ការវាយតម្លៃ ប្រព័ន្ធលើកទឹកចិត្ត និងការពិនិត្យតាមដាននិងវាយតម្លៃ។ ឯកសារនេះ ក៏រួមបញ្ចូលផងដែរ នូវតារាងឧបសម្ព័ន្ធដែលមានឧបករណ៍សម្រាប់ដំណើរការវាយតម្លៃតាមដំណាក់កាលនីមួយៗជាក់លាក់។

សេចក្តីណែនាំប្រតិបត្តិនេះ នឹងដាក់ឱ្យអនុវត្តសាកល្បងរយៈពេល បីឆ្នាំដំបូងនៅក្នុងសាលារៀនដែលស្ថិតនៅក្នុងគម្រោងនានា និងសាលារៀនដែលមានសក្តានុពលផ្សេងទៀត។ ក្រោយការអនុវត្តសាកល្បងនេះ ក្រសួងនឹងធ្វើការកែសម្រួលតាមភាពជាក់ស្តែង ដើម្បីឈានទៅពង្រីកការអនុវត្តទូទាំងប្រទេស។

## ២. គន្លងអាជីពគ្រូបង្រៀន

គន្លងអាជីពគ្រូបង្រៀនមានបីគន្លងគឺ៖ គន្លងបង្រៀន គន្លងគ្រប់គ្រង និងគន្លងឯកទេសអប់រំ។

### ២.១. គន្លងបង្រៀន

គន្លងបង្រៀន ត្រូវបានរៀបចំសម្រាប់បុគ្គលិកអប់រំដែលមានឧបនិស្ស័យក្នុងការបង្រៀន ឆន្ទៈមោះមុត និងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីឱ្យសិស្សមានការរីកចម្រើននៅក្នុងជីវិតសិក្សា និងការងារ។ គន្លងគ្រូបង្រៀនចែកចេញជាបីឋានៈវិជ្ជាជីវៈ៖

- គ្រូល្អ៖ គ្រូល្អ ប្រើប្រាស់វិធីសាស្ត្ររៀន និងបង្រៀនស្របតាមប្រភេទ សាវតារ តម្រូវការ និងការលូតលាស់របស់សិស្ស ដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀនរបស់ខ្លួនប្រសើរឡើងកម្រិតល្អបង្គួរ។ គ្រូល្អ មានការទទួលខុសត្រូវខ្ពស់ និងជាគំរូដល់គ្រូដទៃនៅក្នុងសាលារៀនរបស់ខ្លួន។
- គ្រូឈានមុខ៖ គ្រូឈានមុខ ដឹកនាំ សហការ និងគាំទ្រដល់សហការី ដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀនរបស់ខ្លួនប្រសើរឡើងកម្រិតល្អ។
- គ្រូឆ្នើម៖ គ្រូឆ្នើម បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀនរបស់ខ្លួនប្រសើរឡើងកម្រិតល្អណាស់។ គ្រូឆ្នើម ផ្តួចផ្តើមគំនិតថ្មីៗ និងដឹកនាំសកម្មភាពនៅក្នុងសាលារៀន និងក្រៅសាលារៀន ដើម្បីធ្វើឱ្យសិស្សទាំងអស់ទទួលឱកាសរៀនសូត្រដូចៗគ្នា។

គ្រូបង្រៀន តាំងស៊ប់គ្រប់កម្រិតក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងបម្រើការងារនៅតាមគ្រឹះស្ថានអប់រំសាធារណៈត្រូវឆ្លងកាត់ការវាយតម្លៃ ផ្អែកតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ដើម្បីឈានចូលគន្លងបង្រៀន។

- ❖ **កំណត់សម្គាល់៖** ដើម្បីក្លាយជាគ្រូបង្រៀនក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា បេក្ខជន ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសក្នុងចំណោមសិស្សនិងនិស្សិត និងការបណ្តុះបណ្តាលដំបូងនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។ ក្រោយពេលបញ្ចប់ការបណ្តុះបណ្តាល ពួកគេត្រូវបានបែងចែកឱ្យទៅបម្រើការងារនៅតាមរាជធានី ខេត្ត ក្នុងនាមជាគ្រូបង្រៀនកម្មសិក្សារយៈពេល១២ខែដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រោយពេលធ្វើកម្មសិក្សាបានជោគជ័យ គ្រូបង្រៀនកម្មសិក្សាត្រូវតាំងស៊ប់ក្នុងក្របខណ្ឌគ្រូបង្រៀនក្រសួងអប់រំ យុវជន និងកីឡា។

## ២.២. គន្លងគ្រប់គ្រង

គន្លងគ្រប់គ្រង ត្រូវបានរៀបចំសម្រាប់បុគ្គលិកអប់រំ ដែលមានឧបនិស្ស័យក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀន។ គន្លងនេះ ចែកចេញជាបីឋានៈវិជ្ជាជីវៈដូចខាងក្រោម៖

- នាយកល្អ៖ នាយកល្អ គ្រប់គ្រងនិងដឹកនាំសាលារៀនរបស់ខ្លួន ដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើងកម្រិតល្អបង្គួរ។
- នាយកឈានមុខ៖ នាយកឈានមុខ សម្របសម្រួល សហការ និងគាំទ្រសហការីទាំងអស់នៅក្នុងសាលារៀនរបស់ខ្លួន ដើម្បីរួមចំណែកធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើងកម្រិតល្អ។

- នាយកឆ្នើម៖ នាយកឆ្នើម បង្កើតគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ក្នុងការគ្រប់គ្រងនិងដឹកនាំសាលារៀនរបស់ខ្លួន ដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើងកម្រិតល្អណាស់។

នាយក និងនាយករង ដែលបំពេញការងារនៅគ្រឹះស្ថានសិក្សាអប់រំសាធារណៈ ត្រូវឆ្លងកាត់ការវាយតម្លៃផ្អែកតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ ដើម្បីឈានចូលគន្លងគ្រប់គ្រង។

## ២.៣. គន្លងឯកទេសអប់រំ

គន្លងឯកទេសអប់រំ ត្រូវបានរៀបចំសម្រាប់បុគ្គលិកអប់រំដែលមានឧបនិស្ស័យ និងចំណាប់អារម្មណ៍ផ្អែកត្រិះរិះ ការស្រាវជ្រាវអប់រំ ការតាក់តែងគោលនយោបាយនិងផែនការអប់រំ អភិវឌ្ឍន៍កម្មវិធីសិក្សា អភិវឌ្ឍន៍សម្ភារបង្រៀននិងសៀវភៅសិក្សា គរុកោសល្យនិងវិក្រឹតការ ការវាយតម្លៃលទ្ធផលសិក្សា និងការគ្រប់គ្រងរដ្ឋបាលអប់រំ។ គន្លងឯកទេសអប់រំត្រូវបានចែកចេញជាប្រាំឯកទេសរួមមាន១) គោលនយោបាយនិងផែនការអប់រំ ២) អភិវឌ្ឍន៍កម្មវិធីសិក្សា ៣) ការវាយតម្លៃលទ្ធផលសិក្សា ៤) គរុកោសល្យនិងវិធីសាស្ត្របង្រៀន និង ៥) ការគ្រប់គ្រងរដ្ឋបាលអប់រំ។

គន្លងឯកទេសអប់រំ ចែកចេញជាបីឋានៈវិជ្ជាជីវៈ៖

- អ្នកឯកទេសអប់រំល្អ៖ អ្នកឯកទេសអប់រំល្អ ស្រាវជ្រាវ និងចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ និងផែនការ កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន គរុកោសល្យ ការវាយតម្លៃសិក្សា និងគ្រប់គ្រងរដ្ឋបាលអប់រំ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំ។
- អ្នកឯកទេសអប់រំឈានមុខ៖ អ្នកឯកទេសអប់រំឈានមុខ ស្រាវជ្រាវ និងសហការ ដឹកនាំ និងគាំទ្រសហការីក្នុង ការរៀបចំនិងអនុវត្តគោលនយោបាយនិងផែនការ កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន គរុកោសល្យ ការវាយតម្លៃសិក្សា និងគ្រប់គ្រងរដ្ឋបាលអប់រំ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំ ។
- អ្នកឯកទេសអប់រំឆ្នើម៖ អ្នកឯកទេសអប់រំឆ្នើម ស្រាវជ្រាវ និងបង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយនិងផែនការ កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន គរុកោសល្យ ការវាយតម្លៃសិក្សា និងគ្រប់គ្រងរដ្ឋបាលអប់រំ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំ។

បុគ្គលិកមិនបង្រៀនដែលកំពុងបម្រើការងារនៅតាមការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពថ្នាក់កណ្ដាល ត្រូវឆ្លងកាត់ការវាយតម្លៃផ្អែកតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ ដើម្បីឈានចូលគន្លងឯកទេសអប់រំ។ បុគ្គលិកអប់រំទាំងនោះ មិន

រាប់បញ្ចូលបុគ្គលិកដែលកំពុងបម្រើការនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូឡើយ។

*រូបភាព ១៖ គន្លងអាជីពគ្រូបង្រៀន*




## ២.៤. ការឆ្លងគន្លង

នៅក្នុងដំណាក់កាលសាកល្បងនៃការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនបុគ្គលិកអប់រំដែលត្រូវបានវាយតម្លៃចូលនៅក្នុងគន្លងវិជ្ជាជីវៈជាក់លាក់ណាមួយ មិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្ដូរគន្លងទេ។ ក្រោយពេលបញ្ចប់ការសាកល្បងនេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងចេញសេចក្ដីណែនាំបន្ថែមស្ដីពីការឆ្លងគន្លង។

## ២.៥. គន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

គន្លងអាជីពគ្រូបង្រៀន ជាឋានៈវិជ្ជាជីវៈដែលមិនប៉ះពាល់ដល់មុខតំណែង និងក្របខណ្ឌនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិលទេ។ ដូចគ្នានេះដែរ ការផ្លាស់ប្ដូរមុខតំណែងរបស់គ្រូបង្រៀន នាយក នាយករង ឬមន្ត្រីអប់រំ ក្នុងប្រព័ន្ធមុខងារសាធារណៈ មិនធ្វើឱ្យបាត់បង់ឋានៈវិជ្ជាជីវៈរបស់ខ្លួនឡើយ។

# ៣. លក្ខណៈវិនិច្ឆ័យ

ដើម្បីទទួលបានការដំឡើងឋានៈវិជ្ជាជីវៈនៅក្នុងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន បុគ្គលិកអប់រំត្រូវឆ្លងកាត់ការវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៥ សម្រាប់គន្លងបង្រៀន និងគន្លងគ្រប់

គ្រង។ ដោយឡែក សម្រាប់គន្លងឯកទេសអប់រំ ការវាយតម្លៃត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៤ ។ បុគ្គលិកអប់រំ មិនមានសិទ្ធិទទួលបានការវាយតម្លៃចូលក្នុងគន្លងអាជីពគ្រូបង្រៀនទេ ក្នុងករណីដូចខាងក្រោម៖

- កំពុងជាប់ពាក្យបណ្តឹងផ្លូវច្បាប់ ឬពិរុទ្ធភាព
- មានរឿងអាស្រូវ ឬទំនាស់ធ្ងន់ធ្ងរក្នុងអង្គភាព ឬសហគមន៍។

## ៣.១. លក្ខណៈវិនិច្ឆ័យសម្រាប់គន្លងបង្រៀន

ការវាយតម្លៃបុគ្គលិកអប់រំ ដើម្បីដំឡើងឋានៈវិជ្ជាជីវៈនៅក្នុង **គន្លងបង្រៀន** ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៥ ដូចខាងក្រោម៖

- គុណវុឌ្ឍិ៖ សំដៅដល់បណ្ណំសមត្ថភាពទទួលស្គាល់ជាផ្លូវការក្នុងក្របខណ្ឌអប់រំ ឬវិជ្ជាជីវៈដែលបញ្ជាក់ដោយសញ្ញាបត្រ ឬវិញ្ញាបនបត្រ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់នូវគុណភាពជាផ្លូវការ។
- បទពិសោធការងារ៖ សំដៅដល់បទពិសោធក្នុងការបំពេញការងារជាក់លាក់តាមឋានៈវិជ្ជាជីវៈនីមួយៗ រួមមាន ចំនួនឆ្នាំបង្រៀន ចំនួនគ្រូចេញថ្មីដែលបានជួយណែនាំនិងគាំទ្រ ចំនួនឆ្នាំបម្រើការនៅតាមសាលារៀនដាច់ស្រយាល និងបទពិសោធជាសមាជិកសកម្មសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។
- ស្នាដៃការងារ៖ សំដៅដល់ស្នាដៃវិជ្ជាជីវៈជាក់លាក់ ដែលគ្រូបង្រៀនសម្រេចបាន រួមមានការបោះពុម្ពស្នាដៃស្រាវជ្រាវនៅក្នុងកាលិកបត្រ ចំនួនឯកសារនិងសម្ភារៈជំនួយដល់ការបង្រៀន ចំនួនវីដេអូបង្រៀនតាមប្រព័ន្ធអនឡាញ ការចូលរួមចែករំលែកបទពិសោធក្នុងសិក្ខាសាលា ឬតាមការអញ្ជើញជាក់លាក់ណាមួយ និងស្នាដៃវិជ្ជាជីវៈផ្សេងៗដែលរួមចំណែកដល់ការលើកកម្ពស់គុណភាពវិស័យអប់រំ។
- លទ្ធផលសិក្សារបស់សិស្ស៖ សំដៅដល់ភាគរយសិស្សប្រឡងជាប់តេស្តស្តង់ដា និងអត្រាបោះបង់ការសិក្សានៅក្នុងថ្នាក់ដែលសាមីជនបង្រៀន។ លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានលើកលែងសម្រាប់មត្តេយ្យសិក្សា។
- សមត្ថភាពវិជ្ជាជីវៈ៖ សំដៅដល់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលបានកំណត់នៅក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីឱ្យគ្រូបង្រៀនបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់។

| លក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យរង | បរិយាយ | ឯកសារតាង | សូចនាករ | កម្រិតឋានៈវិជ្ជាជីវៈតាមសូចនាករ |
|---|---|---|---|---|---|
| ១. គុណវុឌ្ឍិ | ១.១. កម្រិតវប្បធម៌ | • សំដៅដល់កម្រិតអប់រំឧត្តមសិក្សាចុងក្រោយដែលបានបញ្ចប់សព្វគ្រប់ និងទទួលស្គាល់ជាលក្ខណៈជាតិ ឬ អន្តរជាតិ រួមមាន បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត ឬ កម្រិតអប់រំដែលមានតម្លៃស្មើ។ កម្រិតអប់រំនេះមិនគិតតែទៅលើមុខវិជ្ជាឯកទេសទេ។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** កម្រិតបរិញ្ញាបត្រ<br>○ **គ្រូឈានមុខ** កម្រិតបរិញ្ញាបត្រជាន់ខ្ពស់<br>○ **គ្រូឆ្នើម** កម្រិតបណ្ឌិត។ | • សញ្ញាបត្រ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ | ១.១.១. កម្រិតបរិញ្ញាបត្រ | ល្អ |
| | | | | ១.១.២. កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | ឈានមុខ |
| | | | | ១.១.៣. កម្រិតបណ្ឌិត | ឆ្នើម |
| | ១.២. កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ | • សំដៅដល់កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ រួមមាន សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យនិងវិក្រឹតការខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ វិទ្យាស្ថានគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំ ឬស្ថាប័នផ្សេងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ សម្រាប់បុគ្គលិកអប់រំដែលបានតាំងស៊ប់ជាគ្រូបង្រៀនកម្រិតឧត្តម ក៏ត្រូវបានរាប់បញ្ចូលថាមានសញ្ញាបត្រវិជ្ជាជីវៈ។<br>• **បញ្ជាក់៖** កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈគ្រូបង្រៀនទាំងអស់មានតម្លៃស្មើគ្នាក្នុងការវាយតម្លៃចូលក្នុងគន្លងបង្រៀនពោលគឺគ្រូមត្តេយ្យ បឋម មូលដ្ឋាន និងឧត្តម នឹងទទួលបានពិន្ទុ ២៥ ដូចគ្នា។ | • សញ្ញាបត្រឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ | ១.២.១. សញ្ញាបត្របណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀនណាមួយ ឬសញ្ញាបត្រដែលមានតម្លៃស្មើ | ឆ្នើម |

| | | | | | |
|---|---|---|---|---|---|
| | ១.៣. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | • សំដៅដល់ការចូលរៀនវគ្គបណ្ដុះបណ្ដាលក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំស្របតាមកម្រិតឋានៈវិជ្ជាជីវៈនីមួយៗ ដើម្បីបំពេញតម្រូវការងារជាក់ស្ដែងនៅកម្រិតសាលារៀន។<br>• **បញ្ជាក់**៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៦ ក្រេឌីត<br>○ **គ្រូឈានមុខ** ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៩ ក្រេឌីត<br>○ **គ្រូផ្ដើម** ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ១២ ក្រេឌីត។ | • ទិន្នន័យពី HRMIS។ | ១.៣.១. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៦ ក្រេឌីត | ល្អ |
| | | | | ១.៣.២. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៩ ក្រេឌីត | ឈានមុខ |
| | | | | ១.៣.៣. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ១២ ក្រេឌីត | ផ្ដើម |
| ២. បទពិសោធការងារ | ២.១. បទពិសោធបង្រៀន | • សំដៅដល់រយៈពេលជាក់លាក់ដែលបុគ្គលិកអប់រំបានបំពេញការងារជាគ្រូបង្រៀនដែលមានភារកិច្ចបង្រៀន។ រយៈពេលនេះមិនរាប់បញ្ចូលពីការព្យួរការងារទេ។<br>• **បញ្ជាក់**៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** មានបទពិសោធបង្រៀនយ៉ាងតិច ៥ ឆ្នាំ<br>○ **គ្រូឈានមុខ** មានបទពិសោធបង្រៀនយ៉ាងតិច ៧ ឆ្នាំ<br>○ **គ្រូផ្ដើម** មានបទពិសោធបង្រៀនយ៉ាងតិច ១០ ឆ្នាំ។ | • លិខិតបង្គាប់ការ ឬ<br>• បំណែងចែកភារកិច្ចប្រចាំឆ្នាំ។ | ២.១.១. មានបទពិសោធបង្រៀន ៥ឆ្នាំ | ល្អ |
| | | | | ២.១.២. មានបទពិសោធបង្រៀន ៧ ឆ្នាំ | ឈានមុខ |
| | | | | ២.១.៣. មានបទពិសោធបង្រៀន ១០ ឆ្នាំ | ផ្ដើម |
| | ២.២. បទពិសោធដឹកនាំបង្ហាត់កម្មសិក្សាការី (គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិត | • សំដៅដល់ចំនួនកម្មសិក្សាការី គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិត ដែលគ្រូសាមីបានផ្ដល់ជំនួយបច្ចេកទេស ផ្សេងៗ ដូចជា វិធីសាស្ត្របង្រៀន ការ ផលិតសម្ភារឧបទេស ការគ្រប់គ្រងថ្នាក់រៀនជាដើម។<br>• កំណត់សម្គាល់៖<br>○ គ្រូកម្មសិក្សាការី សំដៅដល់គ្រូដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ហើយចេញបម្រើការងារជាគ្រូបង្រៀននៅឆ្នាំដំបូង | • លិខិតបង្គាប់ការដែលមានភ្ជាប់នូវរបាយការណ៍នៃការអនុវត្តលិខិតបង្គាប់ការ<br>• សៀវភៅជំបូន្មានអធិការកិច្ច។ | ២.២.១. ដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី(គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិតបាន ៣ នាក់ | ល្អ |
| | | | | ២.២.២. ដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី(គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែល | ឈានមុខ |

| | | | | | |
|---|---|---|---|---|---|
| | | ○ គ្រូកិច្ចសន្យា សំដៅដល់បុគ្គលិកអប់រំដែលមានកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលរយៈពេល ១ ឆ្នាំម្តង ហើយទទួលបានប្រាក់ឧបត្ថម្ភ តែរយៈពេល ១០ ខែ<br>○ គ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិត សំដៅដល់គ្រូបង្រៀនដែលមានសមត្ថភាពបង្រៀននៅទាបដែលកំណត់ដោយប្រធានក្រុមបច្ចេកទេស ឬនាយកសាលា។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** បានជួយដឹកនាំបង្ហាត់បានចំនួនយ៉ាងតិច ៣ នាក់<br>○ **គ្រូឈានមុខ** បានជួយដឹកនាំបង្ហាត់បានចំនួនយ៉ាងតិច ៥ នាក់<br>○ **គ្រូឆ្នើម** បានជួយដឹកនាំបង្ហាត់បានចំនួនយ៉ាងតិច៧ នាក់។ | | មានបច្ចេកទេសបង្រៀននៅមានកម្រិតបាន ៥នាក់ | |
| | | | | ២.២.៣. ដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី(គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិតបាន ៧ នាក់ | ឆ្នើម |
| | ២.៣. បទពិសោធជាគ្រូទទួលបន្ទុកថ្នាក់ | • សំដៅដល់រយៈពេលជាក់លាក់ (យ៉ាងតិច១ឆ្នាំ) ដែលគ្រូបង្រៀនបានបំពេញភារកិច្ចជាគ្រូទទួលបន្ទុកថ្នាក់ មានដូចជាការរៀបចំរដ្ឋបាលថ្នាក់រៀន ការដឹកនាំប្រជុំវាយតម្លៃលើលទ្ធផលសិក្សាសិស្ស និងទំនាក់ទំនងជាមួយមាតាបិតាឬអ្នកអាណាព្យាបាលសិស្សជាដើម។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី តម្រូវឱ្យគ្រូបង្រៀនមានបទពិសោធជាគ្រូបន្ទុកថ្នាក់រយៈពេល ១ ឆ្នាំដូចៗគ្នា ពោលគឺបើមានបទពិសោធរយៈពេល ១ ឆ្នាំនឹងទទួលបានពិន្ទុ១១។ | • លិខិតបង្គាប់ការដែលមានភ្ជាប់នូវរបាយការណ៍នៃការអនុវត្តលិខិតបង្គាប់ការ<br>• បំណែងចែកភារកិច្ច។ | ២.៣.១. ជាគ្រូទទួលបន្ទុកថ្នាក់បាន ១ ឆ្នាំ | ឆ្នើម |
| | ២.៤. បទពិសោធជាប្រធានក្រុម | • សំដៅដល់រយៈពេលជាក់លាក់ដែលគ្រូបានបំពេញភារកិច្ចជាប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា និងបានបំពេញមុខងាររបស់ខ្លួនបានល្អតាមរយៈការដឹកនាំកិច្ចប្រជុំ | • លិខិតបង្គាប់ការដែលមានភ្ជាប់នូវរបាយការណ៍នៃការអនុវត្តលិខិតបង្គាប់ការ<br>• បំណែងចែកភារកិច្ច។ | ២.៤.១. ជាប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជាបាន ៣ ឆ្នាំ | ឆ្នើម |

| | | | | | |
|---|---|---|---|---|---|
| | បច្ចេកទេស ឬ ប្រធានមុខវិជ្ជា | បច្ចេកទេសជាប្រចាំដែលរួមចំណែកក្នុងការអភិវឌ្ឍវិធីសាស្ត្រ បង្រៀន ដោះស្រាយបញ្ហាប្រឈមនានា និងបង្កើនស្មារតីសាមគ្គីភាពផ្ទៃក្នុង ដើម្បីជំរុញដល់ការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលល្អ។<br>• **បញ្ជាក់៖**<br>○ ឋានៈវិជ្ជាជីវៈទាំងបី តម្រូវឱ្យគ្រូបង្រៀនមានបទពិសោធជាប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជារយៈពេល ៣ ឆ្នាំ ដូចៗគ្នា ពោលគឺបើមានបទពិសោធរយៈពេល ៣ ឆ្នាំ នឹងទទួលបានពិន្ទុ ១១។ | | | |
| | ២.៥. បទពិសោធបង្រៀននៅតាមសាលាក្នុងតំបន់ដាច់ស្រយាល ខ្វះគ្រូ ឬ តំបន់ជួបការលំបាក | • សំដៅដល់រយៈពេលជាក់លាក់ដែលគ្រូ បានទៅបំពេញភារកិច្ចបង្រៀននៅតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬតំបន់ជួបការលំបាក។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ត្រូវមានបទពិសោធ ៣ ឆ្នាំ<br>○ **គ្រូឈានមុខ** ត្រូវមានបទពិសោធ ៥ ឆ្នាំ<br>○ **គ្រូឆ្នើម** ត្រូវមានបទពិសោធ ៧ ឆ្នាំ។ | • លិខិតឧទ្ទេសនាម ឬ<br>• លិខិតបង្គាប់ការដែលមានភ្ជាប់នូវរបាយការណ៍នៃការអនុវត្តលិខិតបង្គាប់ការ។ | ២.៥.១. មានបទពិសោធបង្រៀននៅតាមសាលានៅតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាក ៣ ឆ្នាំ | ល្អ |
| | | | | ២.៥.២. មានបទពិសោធបង្រៀននៅតាមសាលានៅតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាក ៥ ឆ្នាំ | ឈានមុខ |
| | | | | ២.៥.៣. មានបទពិសោធបង្រៀននៅតាមសាលានៅតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាក ៧ ឆ្នាំ | ឆ្នើម |

| | | | | | |
|---|---|---|---|---|---|
| | ២.៦. បទពិសោធធ្វើអធិការកិច្ចថ្នាក់រៀន | • សំដៅដល់ចំនួនដងដែលគ្រូបង្រៀនបានធ្វើអធិការកិច្ចផ្ទៃក្នុងសាលា ឬសាលាផ្សេងទៀត ដើម្បីរួមចំណែកលើកកម្ពស់គុណភាពរៀន និងបង្រៀន។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ត្រូវមានបទពិសោធ យ៉ាងតិច ៥ ដង<br>○ **គ្រូឈានមុខ** ត្រូវមានបទពិសោធ យ៉ាងតិច ៩ ដង<br>○ **គ្រូឆ្នើម** ត្រូវមានបទពិសោធ យ៉ាងតិច ១៤ ដង។ | • លិខិតបង្គាប់ការចុះអធិការកិច្ច | ២.៦.១. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនបាន ៥ ដង | ល្អ |
| | | | | ២.៦.២. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនបាន ៩ ដង | ឈានមុខ |
| | | | | ២.៦.៣. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនបាន ១៤ ដង | ឆ្នើម |
| | ២.៧. សមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន | • សំដៅដល់ការចូលជាសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈនៃបុគ្គលិកអប់រំ ឬគ្រូបង្រៀន ដែលមានជំនាញឯកទេសតួនាទី និងភារកិច្ចស្រដៀងគ្នា និងធ្វើការរួមគ្នា ដើម្បីចែករំលែកបទពិសោធ បច្ចេកទេស វិធីសាស្ត្រ របកគំហើញ ឬព័ត៌មានថ្មីៗ សំដៅពង្រឹងប្រសិទ្ធភាពការរៀន និងបង្រៀន។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ចូលរួមជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ<br>○ **គ្រូឈានមុខ** សម្របសម្រួលសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈ<br>○ **គ្រូឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងការដឹកនាំសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ | • លិខិតបង្គាប់ការ ប័ណ្ណសមាជិកភាព ឬវិញ្ញាបនបត្រដែលបញ្ជាក់ទទួលស្គាល់ដោយប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន។ | ២.៧.១. ចូលរួមជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ | ល្អ |
| | | | | ២.៧.២. សម្របសម្រួលសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈ | ឈានមុខ |
| | | | | ២.៧.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងការដឹកនាំសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ | ឆ្នើម |
| ៣. ស្នាដៃការងារ | ៣.១. ការបោះពុម្ពស្នាដៃស្រាវជ្រាវប្រតិបត្តិ | | | ៣.១.១. ចំនួន ១ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ | ល្អ |

<table>
<tr>
<td rowspan="4"></td>
<td rowspan="2"></td>
<td rowspan="2">• សំដៅដល់ចំនួនអត្ថបទ ឬរបាយការណ៍ស្រាវជ្រាវប្រតិបត្តិដែលគ្រូបង្រៀនបានបោះពុម្ព មានលក្ខណៈជាបុគ្គល (ស្នាដៃទោល) ឬ ក្រុម (អ្នកស្រាវជ្រាវទី១)<br>• កំណត់សម្គាល់៖<br>ការស្រាវជ្រាវប្រតិបត្តិ គឺជាការស្រាវជ្រាវខ្នាតតូចដែលមានលក្ខណៈវិទ្យាសាស្ត្រ និងឆ្លងកាត់ការវិភាគស៊ីជម្រៅលើបញ្ហាជាក់លាក់ដែលកំពុងកើតមាន ក្នុងការអនុវត្តការងារប្រចាំថ្ងៃ ដើម្បីស្វែងរកបទអន្តរាគមន៍សមស្រប និងទាន់ពេលវេលា។<br>• បញ្ជាក់៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ គ្រូល្អ បានបោះពុម្ពស្នាដៃស្រាវជ្រាវប្រតិបត្តិបានយ៉ាងតិចចំនួន ១ អត្ថបទ<br>○ គ្រូឈានមុខ បានបោះពុម្ពស្នាដៃស្រាវជ្រាវប្រតិបត្តិបានយ៉ាងតិចចំនួន ៣ អត្ថបទ<br>○ គ្រូឆ្នើម បានបោះពុម្ពស្នាដៃស្រាវជ្រាវប្រតិបត្តិបានយ៉ាងតិចចំនួន ៥ អត្ថបទ។</td>
<td rowspan="2">• អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ ដែលបានបោះពុម្ពផ្សាយ។</td>
<td>៣.១.២. ចំនួន ៣ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ</td>
<td>ឈានមុខ</td>
</tr>
<tr>
<td>៣.១.៣. ចំនួន ៥ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ</td>
<td>ឆ្នើម</td>
</tr>
<tr>
<td rowspan="2">៣.២. ការផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន</td>
<td rowspan="2">• សំដៅដល់ចំនួនឯកសារដែលគ្រូបានផលិត និងចងក្រងរួមមាន វិធីសាស្ត្របង្រៀន ឬរបៀបផលិតសម្ភារឧបទេសជាក់លាក់ណាមួយជាដើម ដែលទទួលស្គាល់ដោយសហការី និងគណៈគ្រប់គ្រងសាលា ដើម្បីលើកកម្ពស់គុណភាពរៀន និងបង្រៀន។<br>• បញ្ជាក់៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ គ្រូល្អ បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ១ ស្នាដៃ</td>
<td rowspan="2">• ឯកសារដែលផលិតបានមានការទទួលស្គាល់ពីគណៈគ្រប់គ្រងសាលារៀន ឬប្រធានក្រុមសហគមន៍វិជ្ជាជីវៈ។</td>
<td>៣.២.១. បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ១ ស្នាដៃ</td>
<td>ល្អ</td>
</tr>
<tr>
<td>៣.២.២. បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ៣ ស្នាដៃ</td>
<td>ឈានមុខ</td>
</tr>
</table>

| | | | | | |
|---|---|---|---|---|---|
| | | ○ **គ្រូឈានមុខ** បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ៣ ស្នាដៃ<br>○ **គ្រូឆ្នើម** បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ៥ ស្នាដៃ។ | | ៣.២.៣. បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ៥ ស្នាដៃ | ឆ្នើម |
| | ៣.៣. ការផលិត និងផ្សព្វផ្សាយការបង្រៀនសិស្សតាមប្រព័ន្ធអនឡាញ | • សំដៅដល់ចំនួនមេរៀនដែលគ្រូបានផលិត និងផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញដូចជា បណ្តាញសង្គម ហ្វេសប៊ុក ធ្វីតធ័រ យូធូប តេឡេក្រាមជាដើម។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ១ មេរៀន<br>○ **គ្រូឈានមុខ** បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ៣ មេរៀន<br>○ **គ្រូឆ្នើម** បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ៥ មេរៀន។ | • វិដេអូដែលផលិតបានដោយមានការទទួលស្គាល់ពីគណៈកម្មការបច្ចេកទេសកម្រិតសាលារៀន។ | ៣.៣.១. បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ១ មេរៀន | ល្អ |
| | | | | ៣.៣.២. បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ៣ មេរៀន | ឈានមុខ |
| | | | | ៣.៣.៣. បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ៥ មេរៀន | ឆ្នើម |
| | ៣.៤. ការចូលរួម និងចែករំលែកបទពិសោធនៅក្នុងសិក្ខាសាលា សន្និសីទ វគ្គបណ្តុះបណ្តាលឬ ការអញ្ជើញពិសេសណាមួយ | • សំដៅដល់ចំនួនកម្មវិធី សិក្ខាសាលា សន្និសីទ ឬវគ្គបណ្តុះបណ្តាលដែលគ្រូចូលរួមធ្វើបទបង្ហាញ ឬជាវាគ្មិនកិត្តិយសដើម្បីចែករំលែកស្នាដៃ បទពិសោធការងារ ឬរបកគំហើញថ្មីដែលខ្លួនទទួលបានជោគជ័យក្នុងអាជីពការងាររបស់ខ្លួន។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី<br>○ **គ្រូល្អ** បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ៣ កម្មវិធី<br>○ **គ្រូឈានមុខ** បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ៥ កម្មវិធី | • លិខិតឧទ្ទេសនាម ឬលិខិតអញ្ជើញ ដែលបញ្ជាក់ពីការធ្វើបទបង្ហាញ ឬជាវាគ្មិន។ | ៣.៤.១. ចំនួន ៣ កម្មវិធី | ល្អ |
| | | | | ៣.៤.២. ចំនួន ៥ កម្មវិធី | ឈានមុខ |
| | | | | ៣.៤.៣. ចំនួន ១០ កម្មវិធី | ឆ្នើម |

| | | | | | |
|---|---|---|---|---|---|
| | | ○ **គ្រូឆ្នើម** បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ១០ កម្មវិធី | | | |
| | ៣.៥. ស្នាដៃវិជ្ជាជីវៈជាក់លាក់ផ្សេងទៀត | • សំដៅដល់ស្នាដៃវិជ្ជាជីវៈ ដែលគ្រូសម្រេចបាន ដូចជា៖<br>○ ការបង្វឹកបង្ហាត់សិស្សចូលរួមការប្រឡងកម្រិតជាតិ និងអន្តរជាតិទទួលបានលទ្ធផលមេដាយសំរិទ្ធ ប្រាក់ ឬមាស<br>○ ការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួង ក្នុងការធានានិរន្តរភាពនៃការរៀន និងបង្រៀនក្នុងពេលមានវិបត្តិ<br>○ សមិទ្ធផលវិជ្ជាជីវៈផ្សេងទៀត។<br>• **បញ្ជាក់៖**<br>○ ស្នាដៃទាំងអស់មានតម្លៃពិន្ទុស្មើគ្នានៅក្នុងឋានៈវិជ្ជាជីវៈទាំងបី<br>○ ស្នាដៃដែលត្រូវបានវាយតម្លៃម្តងរួចហើយ មិនត្រូវបានរាប់បញ្ចូលក្នុងការវាយតម្លៃសម្រាប់ដំឡើងឋានៈវិជ្ជាជីវៈបន្ទាប់ទៀតទេ។ | • ភស្តុតាងជាក់ស្តែង | ៣.៥.១. មានស្នាដៃដែល ទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬរាជរដ្ឋាភិបាល | ឆ្នើម |
| ៤. លទ្ធផលសិក្សារបស់សិស្ស<br>*ករណីលើកលែង៖ សម្រាប់មត្តេយ្យសិក្សា លក្ខណៈវិនិច្ឆ័យនេះត្រូវលើកលែង | ៤.១. ភាគរយសិស្សក្នុងសាលាដែលខ្លួនបង្រៀនប្រឡងជាប់តេស្តស្តង់ដាកើនឡើងធៀបលទ្ធផលដើមឆ្នាំ | • សំដៅដល់ភាគរយសិស្សនៅក្នុងថ្នាក់របស់ខ្លួន ប្រឡងជាប់តេស្តស្តង់ដាកើនឡើងយ៉ាងហោចណាស់ចាប់ពី ៣០ ភាគរយ ៥០ភាគរយ និង៧០ភាគរយធៀបនឹងលទ្ធផលតេស្តដើមឆ្នាំសិក្សា។ សម្រាប់គ្រូនៅកម្រិតបឋមសិក្សា លទ្ធផលតេស្តស្តង់ដាគ្របដណ្តប់លើ សិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀន។ ចំណែកឯកម្រិតមធ្យមសិក្សា លទ្ធផលតេស្តស្តង់ដាគ្របដណ្តប់លើមុខវិជ្ជា និងថ្នាក់ដែលខ្លួនបង្រៀន។<br>• **កំណត់សម្គាល់៖** | • លទ្ធផលតេស្តដើមឆ្នាំ និងចុងឆ្នាំ។ | ៤.១.១. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្ត ស្តង់ដាកើនឡើងយ៉ាងហោចណាស់ ៣០ភាគរយធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | ល្អ |

| | | | | | |
|---|---|---|---|---|---|
| | | ○ តេស្តស្តង់ដា សំដៅដល់តេស្តដែលរៀបចំដោយ សាលារៀនសាមី ដោយបំពេញស្តង់ដា និងនីតិវិធីតាមការណែនាំរបស់នាយកដ្ឋានធានាគុណភាពអប់រំ<br>○ បើគ្រូបង្រៀនមុខវិជ្ជាឯកទេសច្រើនកម្រិតថ្នាក់ ត្រូវយកលទ្ធផលតេស្តស្តង់ដានៅកម្រិតថ្នាក់ខ្ពស់ជាងគេ។ បើនៅក្នុងកម្រិតថ្នាក់ដែលខ្ពស់ជាងគេនោះមានចំនួនលើសពីមួយថ្នាក់ ត្រូវរកមធ្យមភាគលទ្ធផលតេស្តស្តង់ដារួម<br>○ បើគ្រូបង្រៀនខុសមុខវិជ្ជាឯកទេស ត្រូវយកលទ្ធផលតេស្តស្តង់ដា លើមុខវិជ្ជាដែលគាត់កំពុងបង្រៀន<br>○ បើគ្រូបង្រៀនច្រើនមុខវិជ្ជា ហើយមានមុខវិជ្ជាមួយត្រូវនឹងឯកទេសរបស់ខ្លួន ត្រូវយកលទ្ធផលតេស្តស្តង់ដា លើមុខវិជ្ជាឯកទេសនោះ<br>○ បើគ្រូបង្រៀនច្រើនមុខវិជ្ជាហើយមិនត្រូវឯកទេស ត្រូវយកលទ្ធផលតេស្តស្តង់ដា លើមុខវិជ្ជាណាមួយដែលខ្លួនគិតថាមានភាពជឿជាក់ជាងគេ។<br>• **បញ្ជាក់**៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្តស្តង់ដាកើនឡើងយ៉ាងហោចណាស់ ៣០ ភាគរយធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ (X1ជាលទ្ធផលតេស្តដើមឆ្នាំ X2 ជាលទ្ធផលតេស្តចុងឆ្នាំ និង X2-X1 ជាកំណើនលទ្ធផលតេស្តប្រចាំឆ្នាំ ដូច្នេះគ្រូល្អ គឺ ៣០% <= X2 - X1<៥០%) | | ៤.១.២. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្ត ស្តង់ដាកើនឡើងយ៉ាងហោចណាស់ពី ៥០ ភាគរយ ដល់ក្រោម៧០ភាគរយ ធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | ឈានមុខ |
| | | | | ៤.១.៣. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្ត ស្តង់ដាកើនឡើងយ៉ាងហោចណាស់ពី ៧០ ភាគរយឡើងទៅធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | ឆ្នើម |

| | | | | | |
|---|---|---|---|---|---|
| | | ○ **គ្រូឈានមុខ** ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្តស្តង់ដាកើនឡើងយ៉ាងហោចណាស់ពី ៥០ភាគរយ ដល់ក្រោម៧០ភាគរយ ធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ (X1ជាលទ្ធផលតេស្តដើមឆ្នាំ X2 ជាលទ្ធផលតេស្តចុងឆ្នាំ និងX2-X1 ជាកំណើនលទ្ធផលតេស្តប្រចាំឆ្នាំ ដូច្នេះគ្រូល្អ គឺ ៥0%<=X2 - X1<៧0%)<br>○ **គ្រូឆ្នើម** ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្តស្តង់ដាកើនឡើងយ៉ាងហោចណាស់ពី ៧០ភាគរយឡើងទៅធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ (X1ជាលទ្ធផលតេស្តដើមឆ្នាំ X2 ជាលទ្ធផល តេស្តចុងឆ្នាំ និងX2-X1 ជាកំណើនលទ្ធផលតេស្តប្រចាំឆ្នាំ ដូច្នេះគ្រូល្អ គឺ X2 - X1>=៧0%)។ | | | |
| | ៤.២. អត្រាសិស្សបោះបង់ | • សំដៅដល់ផលសងនៃអត្រាឡើងថ្នាក់ និងអត្រាត្រួតថ្នាក់នឹង ១០០ ភាគរយតាមកម្រិតថ្នាក់ដែលខ្លួនបង្រៀន។<br>• **ករណីលើកលែង**៖ សម្រាប់ថ្នាក់ទី១២ សូចនាករនេះ សំដៅដល់ផលសងចំនួនសិស្សចូលរៀនដើមឆ្នាំ និងចំនួនសិស្សបានប្រឡងបញ្ចប់ឆ្នាំ។<br>• **បញ្ជាក់**៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀន៖<br>- សម្រាប់បឋមសិក្សា យ៉ាងច្រើនណាស់ ២ ភាគរយ | • អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀនឆ្នាំសិក្សាកន្លងទៅ។ | ៤.២.១. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀន៖<br>- សម្រាប់បឋមសិក្សា យ៉ាងច្រើនណាស់ ២ ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៩ ភាគរយ | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | - សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៩ ភាគរយ<br>○ **គ្រូឈានមុខ** អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀន៖<br>- សម្រាប់បឋមសិក្សា យ៉ាងច្រើនណាស់ ១ ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៦ ភាគរយ<br>○ **គ្រូឆ្នើម** អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀន៖<br>- សម្រាប់បឋមសិក្សា 0 ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៣ ភាគរយ។ | | ៤.២.២. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀន៖<br>- សម្រាប់បឋមសិក្សា យ៉ាងច្រើនណាស់ ១ ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៦ ភាគរយ | ឈានមុខ |
| | | | | | | ៤.២.៣. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀន៖<br>- សម្រាប់បឋមសិក្សា 0 ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់៣ភាគរយ | ឆ្នើម |
| ៥. សមត្ថភាពវិជ្ជាជីវៈ | ៥.១. វិជ្ជាសម្បទា | ចំណេះដឹងអំពីសិស្ស | ៥.១.១. ការយល់ដឹងអំពីសិស្ស៖ ប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះ ឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងដឹងពីរបៀបដោះស្រាយ | • សំដៅដល់ចំណេះដឹងអំពីសិស្ស រួមមាន ប្រភេទ តម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សា ឥរិយាបថសិក្សា និងកត្តាផ្សេងៗដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស ដូចជា យេនឌ័រ សេដ្ឋកិច្ចសង្គម ក្រុមជនជាតិ និងពិការភាព ព្រមទាំងដំណោះស្រាយ។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀប ដោះស្រាយ<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗ ដែល | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.១.១.១. ពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តា ផ្សេងៗដែលជះ ឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ<br>○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ។ | | ៥.១.១.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ឈានមុខ |
| | | | | | • បង្ហាញពីវិធីសាស្ត្រថ្មីដែលបង្កើតបាន។ | ៥.១.១.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និង នវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តា ផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ឆ្នើម |
| | | ចំណេះដឹងអំពីខ្លួនសាលារៀន | ៥.១.២. ការយល់ដឹងគោលនយោបាយអប់រំ គោលដៅអប់រំ គោលបំណងអប់រំចំណេះទូទៅ និងកម្មវិធីសិក្សា | • សំដៅដល់ចំណេះដឹងអំពីចក្ខុវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឬគោលនយោបាយអប់រំចំណេះទូទៅ និងច្បាប់អប់រំ ដែលស្តែងចេញតាមរយៈសកម្មភាពដូចខាងក្រោម៖<br>○ ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ<br>○ ពណ៌នាបានពីយុទ្ធសាស្ត្ររបស់ក្រសួង ឬរាជរដ្ឋាភិបាលដើម្បី ធ្វើឱ្យសម្រេចគោលនយោបាយ | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន | ៥.១.២.១. ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យ សម្រេចគោលដៅទាំងនោះ | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | អប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ<br>○ ចូលរួមផ្សព្វផ្សាយអំពីគោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ<br>○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាព ច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ។ | | ៥.១.២.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធ សាស្ត្រដែលធ្វើឱ្យ សម្រេចគោលដៅទាំងនោះ | ឈានមុខ |
| | | | | | • អនុសាសន៍គោលនយោបាយតាមរយៈការស្រាវជ្រាវជាក់លាក់<br>• សំណើសង្ខេបលើការរៀបចំគោលនយោបាយ | ៥.១.២.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធ សាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៥.១.៣. ការយល់ដឹងអំពីការរៀបចំផែនការ និង កិច្ចតែងការបង្រៀន | • សំដៅដល់ចំណេះដឹង អំពី ការរៀបចំផែនការ និង កិច្ចតែងការបង្រៀន ដូចខាងក្រោម៖ របៀបសរសេរផែនការបង្រៀន<br>○ ការកំណត់វត្ថុបំណង និងធាតុរបស់វា<br>○ ការប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល<br>○ ការកំណត់យុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស<br>○ ការផលិតនិងប្រើប្រាស់សម្ភាររៀន និងបង្រៀន។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ប្រាប់បានពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀនជាដើម។<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាពីរបៀបរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន<br>○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.១.៣.១. ប្រាប់បានពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន ជាដើម | ល្អ |
| | | | | | | ៥.១.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាពីរបៀបរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន | ឈានមុខ |
| | | | | | | ៥.១.៣.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៥.១.៤. ការយល់ដឹងអំពីខ្លឹមសារកម្មវិធីសិក្សា | • សំដៅដល់ចំណេះដឹងអំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា ដែលបានកំណត់ច្បាស់លាស់នូវលទ្ធផលរំពឹងទុកតាមមេរៀន នីមួយៗ រយៈពេលបង្រៀន ព្រមទាំងវិធីសាស្ត្រវាយតម្លៃ។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ពន្យល់បានអំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យយល់ច្បាស់អំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស<br>○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាព ច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស។ | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.១.៤.១. ពន្យល់បានអំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ល្អ |
| | | | | | | ៥.១.៤.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យយល់ច្បាស់អំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ឈានមុខ |
| | | | | | | ៥.១.៤.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពី ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៥.១.៥. ការយល់ដឹងអំពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត | • សំដៅដល់ចំណេះដឹងអំពីវិធីសាស្រ្តសម្បូរបែបក្នុងការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ពណ៌នាបានពីវិធីសាស្រ្តសម្បូរបែបក្នុងការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យ ពណ៌នាបានពីវិធីសាស្រ្តសម្បូរបែបសម្រាប់ បញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន<br>○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីវិធីសាស្រ្តសម្បូរបែបសម្រាប់ បញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន។ | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.១.៥.១. ពណ៌នាបានពីវិធីសាស្រ្តសម្បូរបែបក្នុងការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្សរៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ល្អ |
| | | | | | | ៥.១.៥.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីវិធីសាស្រ្តសម្បូរបែបសម្រាប់បញ្ជ្រាបខ្លឹមសារពី មុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ឈានមុខ |
| | | | | | | ៥.១.៥.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីវិធីសាស្រ្តសម្បូរបែបសម្រាប់ បញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ចំណេះដឹងអំពីរបៀបរៀនរបស់សិស្ស | ៥.១.៦. ការយល់ដឹងអំពីបរិស្ថានសិក្សាក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ | • សំដៅដល់ចំណេះដឹងអំពីបរិស្ថានរូបវន្ត ដូចជា ការរៀបចំថ្នាក់រៀនឱ្យមានអនាម័យនិងឱ្យសិស្សចង់រៀន និងបរិស្ថានផ្លូវចិត្តសិស្ស រួមមាន ភាពក្លាហាន ទឹកមុខសិស្សក្នុងការរៀន និងការចូលរួមក្នុងសកម្មភាពរៀន ព្រមទាំងវិធីដែលសហគមន៍ចូលរួម។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង<br>○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីវិធីសាស្ត្រដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង។ | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.១.៦.១. ពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ល្អ |
| | | | | | | ៥.១.៦.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ឈានមុខ |
| | | | | | | ៥.១.៦.៣.ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីវិធីសាស្ត្រដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ឆ្នើម |
| | | | ៥.១.៧. ការយល់ដឹងអំពីរបៀបរៀនទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | • សំដៅដល់ចំណេះដឹងអំពីទ្រឹស្តីផ្សេងៗដែលពណ៌នាពីភាពផ្សេងៗគ្នានៃរបៀបរៀនរបស់សិស្ស រួមមាន ការស្តាប់ ការមើល និងការអនុវត្ត ទេពកោសល្យពីកំណើត និងភាពលឿន ឬយឺតក្នុងការសិក្សារបស់សិស្ស។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.១.៧.១. ពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | ល្អ |
| | | | | | | ៥.១.៧.២. សម្របសម្រួលសហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | ឈានមុខ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ○ **គ្រូឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យនិងល្បឿនសិក្សារបស់សិស្ស។ | | ៥.១.៧.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពី ទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យនិងល្បឿនសិក្សារបស់សិស្ស | ឆ្នើម |
| | ៥.២. បំណិនសម្បទា | ការរៀបចំផែនការ និងការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា | ៥.២.១. ការអនុវត្តផែនការបង្រៀន កិច្ចតែងការបង្រៀនដោយបញ្ជាក់អំពីលទ្ធផលសិក្សារំពឹងទុកស្របតាមសមត្ថភាពសិស្ស និងការវាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព | • សំដៅដល់បំណិនក្នុងការបង្រៀនផ្អែកតាមផែនការប្រចាំសប្តាហ៍ ខែ និងឆ្នាំ និងកិច្ចតែងការបង្រៀនដែលមានសេចក្តីពណ៌នាបញ្ជាក់ពីវត្ថុបំណងមេរៀនរបៀបវាយតម្លៃលទ្ធផលសិក្សា សកម្មភាពសិស្ស គ្រូនិងខ្លឹមសារមេរៀនដើម្បីគាំទ្រវត្ថុបំណងមេរៀនបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** រៀបចំផែនការបង្រៀន និង កិច្ចតែងការបង្រៀនច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍ កំណត់<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យរៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀន ច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់<br>○ **គ្រូឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការរៀបចំផែនការបង្រៀននិងកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់និងត្រឹមត្រូវតាមគោលការណ៍កំណត់។ | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.២.១.១. រៀបចំផែនការបង្រៀន និង កិច្ចតែងការបង្រៀនច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ល្អ |
| | | | | | | ៥.២.១.២.សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យរៀបចំផែនការបង្រៀន និង កិច្ចតែងការបង្រៀន ច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ឈានមុខ |
| | | | | | | ៥.២.១.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការរៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀន ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៥.២.២. ការរៀបចំសម្ភាររៀន និងបង្រៀនដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ | • សំដៅដល់បំណិនក្នុងការរៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អ។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** រៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព<br>○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យរៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព<br>○ **គ្រូឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ដើម្បីរៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព ។ | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.២.២.១. រៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ល្អ |
| | | | | | | ៥.២.២.២. សម្របសម្រួលសហការ និងគាំទ្រសហការីឱ្យរៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ឈានមុខ |
| | | | | | | ៥.២.២.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ដើម្បីរៀបចំសម្ភាររៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ឆ្នើម |
| | | | ៥.២.៣. ការប្រើវិធីសាស្ត្រសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | • សំដៅដល់បំណិនក្នុងការប្រើប្រាស់វិធីសាស្ត្រសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស រួមមាន ការកសាងសំណួរតេស្តដែលមានទម្រង់ និងរយៈពេល សមស្របសម្រាប់សិស្ស ការជ្រើសរើសបញ្ជីសំណួរពីសៀវភៅផ្សេងៗ ដែលមានទម្រង់សំណួរ និងរយៈពេល សមស្របសម្រាប់សិស្សឆ្លើយ ការបង្ហាញអត្រាកំណែ តេស្តនិងការកែចម្លើយរបស់សិស្សបានត្រឹមត្រូវ និង ការកំណត់បានយ៉ាងច្បាស់ពីលទ្ធផលតេស្ត ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស។<br>• **បញ្ជាក់**៖សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **គ្រូល្អ** ប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | • លទ្ធផលវាយតម្លៃកម្រិតសាលារៀន។ | ៥.២.៣.១. ប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ល្អ |
| | | | | | | ៥.២.៣.២. សម្របសម្រួលសហការ និងគាំទ្រសហការីឱ្យប្រើប្រាស់វិធីសាស្ត្រសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ឈានមុខ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ○ **គ្រូឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស<br>○ **គ្រូផ្ទើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ | | ៥.២.៣.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ផ្ទើម |
| | | | | ○ ពណ៌នាបានពីយុទ្ធសាស្ត្រ របស់ក្រសួងឬរាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យសម្រេចគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ<br>○ ចូលរួមផ្សព្វផ្សាយអំពីគោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ<br>○ **អ្នកឯកទេសអប់រំឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ។ | | ៤.១.២.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ឈានមុខ |
| | | | | | | ៤.១.២.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ។ | ឆ្នើម |
| | | គរុកោសល្យ និងវិធីសាស្ត្របង្រៀន | ៤.១.៣. ចំណេះដឹងផ្នែកគរុកោសល្យនិងវិធីសាស្ត្របង្រៀន | • សំដៅដល់ចំណេះដឹងបញ្ញត្តិ ឬទ្រឹស្តីពាក់ព័ន្ធនឹងគរុកោសល្យ និងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប រួមមាន៖ ការបង្រៀនតាមបែបសហការ ការបង្រៀនតាមបែបបិរះរក ការបង្រៀនតាមបែប ៥E ការបង្រៀនផ្អែកលើបញ្ញត្តិ ការបង្រៀនសិស្សរៀនយឺត និងវិធីសាស្ត្រផ្សេងៗ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ | ៤.១.៣.១. ពណ៌នាបានពីបញ្ញត្តិ ឬទ្រឹស្តីពាក់ព័ន្ធនឹងគរុកោសល្យនិងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ទៀត ដើម្បីសម្រេចបានតាមលទ្ធផលរំពឹងទុកក្នុងកម្មវិធីសិក្សា និងបំណិនសម្រាប់សតវត្សទី២១។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ពណ៌នាបានពីបញ្ញត្តិ ឬទ្រឹស្តីពាក់ព័ន្ធនឹងគរុកោសល្យនិងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីបញ្ញត្តិ ឬទ្រឹស្តីពាក់ព័ន្ធនឹងគរុកោសល្យនិងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប<br>○ **អ្នកឯកទេសអប់រំឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគរុកោសល្យនិងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប។ | | ៤.១.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីបញ្ញត្តិ ឬទ្រឹស្តីពាក់ព័ន្ធនឹងគរុកោសល្យ និងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប | ឈានមុខ |
| | | | | | | ៤.១.៣.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និង ន វានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគរុកោសល្យនិងវិធីសាស្ត្របង្រៀនប្រកបដោយភាពសម្បូរបែប។ | ឆ្នើម |
| | | គរុកោសល្យ និងវិធីសាស្ត្របង្រៀន | ៤.១.៤. ចំណេះដឹងលើការផលិតនិងប្រើប្រាស់សម្ភារៈរៀននិងបង្រៀន | • សំដៅដល់ចំណេះដឹងអំពីរបៀបផលិតនិងប្រើប្រាស់ សម្ភារៈបង្រៀននិងរៀន ដើម្បីគាំទ្រដល់ការបង្រៀន និងរៀន។<br>• បញ្ជាក់៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ពណ៌នាបានពីរបៀបផលិតនិងប្រើប្រាស់ សម្ភារៈបង្រៀននិងរៀន<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីរបៀបផលិតនិងប្រើប្រាស់សម្ភារៈបង្រៀននិងរៀន | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ | ៤.១.៤.១. ពណ៌នាបានពីរបៀបផលិតនិងប្រើប្រាស់សម្ភារៈបង្រៀននិងរៀន | ល្អ |
| | | | | | | ៤.១.៤.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីរបៀប ផលិតនិងប្រើប្រាស់ សម្ភារៈបង្រៀននិងរៀន | ឈានមុខ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ○ **អ្នកឯកទេសអប់រំឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីរបៀបផលិតនិងប្រើប្រាស់ សម្ភារៈបង្រៀននិងរៀន។ | | ៤.១.៤.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ដើម្បីលើកកម្ពស់ការយល់ដឹងពីរបៀបផលិតនិងប្រើប្រាស់សម្ភារៈបង្រៀននិងរៀន។ | ឆ្នើម |
| | ៤.២. បំណិនសម្បទា | គរុកោសល្យ និងវិធីសាស្ត្របង្រៀន | ៤.២.១. ការផលិត និងប្រើប្រាស់សម្ភាររៀន និងបង្រៀនសម្បូរបែប | • សំដៅដល់បំណិនក្នុងការផលិត និងប្រើប្រាស់សម្ភារសម្បូរបែប ដើម្បីគាំទ្រដល់ការរៀននិងបង្រៀន។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ផលិត និងប្រើប្រាស់សម្ភារបង្រៀននិងរៀន<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យផលិតនិងប្រើប្រាស់សម្ភារបង្រៀននិងរៀន<br>○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ ការផលិតនិងប្រើប្រាស់សម្ភារបង្រៀននិងរៀន។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ | ៤.២.២.១. ផលិត និងប្រើប្រាស់សម្ភារបង្រៀននិងរៀន | ល្អ |
| | | | | | | ៤.២.២.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យផលិតនិងប្រើប្រាស់សម្ភារបង្រៀននិងរៀន | ឈានមុខ |
| | | | | | | ៤.២.២.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការផលិតនិងប្រើប្រាស់សម្ភារបង្រៀននិងរៀន។ | ឆ្នើម |
| | | | ៤.២.២. ការរៀបចំវិធីសាស្ត្របង្រៀនសិស្សរៀនយឺត | • សំដៅដល់បំណិនក្នុងការរៀបចំ ឬចងក្រងវិធីសាស្ត្រ ដើម្បីជួយសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** រៀបចំ ឬចងក្រងវិធីសាស្ត្រ ដើម្បីជួយសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យរៀបចំ ឬចងក្រង វិធីសាស្ត្រ ដើម្បីជួយសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព<br>○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់វិធីសាស្ត្របង្រៀនសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ | ៤.២.៣.១. រៀបចំ ឬចងក្រងវិធីសាស្ត្រ ដើម្បីជួយសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព | ល្អ |
| | | | | | | ៤.២.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យរៀបចំ ឬចងក្រងវិធីសាស្ត្រ ដើម្បីជួយសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព | ឈានមុខ |
| | | | | | | ៤.២.៣.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់វិធីសាស្ត្របង្រៀនសិស្សរៀនយឺតប្រកបដោយប្រសិទ្ធភាព។ | ឆ្នើម |

| | | | | | | |
|---|---|---|---|---|---|---|
| | | បច្ចេកវិទ្យាព័ត៌មានវិទ្យា | ៤.២.៣. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ | • សំដៅដល់បំណិនក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា ដូចជាការរៀបចំឧបករណ៍ និងប្រមូលទិន្នន័យ និងការវិភាគទិន្នន័យជាដើម។<br>• **បញ្ជាក់**៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា<br>○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំ | ៤.២.៣.១. ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា | ល្អ |
| | | | | | ៤.២.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា | ឈានមុខ |
| | | | | | ៤.២.៣.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា។ | ឆ្នើម |
| | ៤.៣. ចរិយាសម្បទា | | ៤.៣.១. ប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ | • សំដៅដល់ចរិយាសម្បទាក្នុងការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ តាមរយៈ៖<br>○ ការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ<br>○ ការពង្រឹងសាមគ្គីភាព<br>○ ការគោរពវិន័យការងារ<br>○ ការរក្សាការសម្ងាត់វិជ្ជាជីវៈ ភក្តីភាពចំពោះអង្គភាព ផ្តល់តម្លៃដល់សហការី មិនមានការរើសអើងមិនប្រើហិង្សា និងសីលធម៌រស់នៅល្អ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំ | ៤.៣.១.១. ប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ | ល្អ |
| | | | | | ៤.៣.១.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ | ឈានមុខ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ○ ការប្រកាន់ខ្ជាប់នូវសុភវិនិច្ឆ័យ យុត្តិធម៌ តម្លាភាព និងការពិគ្រោះយោបល់ផ្អែកលើភស្តុតាងជាក់ស្តែង។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ<br>○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីជំរុញការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ។ | | ៤.៣.១.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីជំរុញការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ | ឆ្នើម |
| | | ៤.៣.២. ប្តេជ្ញាចិត្ត | • សំដៅដល់ការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ។<br>• **បញ្ជាក់៖ សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖**<br>○ **អ្នកឯកទេស អប់រំល្អ** បង្ហាញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យមានការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ<br>• **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីជំរុញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅលើកកម្ពស់គុណភាពអប់រំ។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំ | ៤.៣.២.១. បង្ហាញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ | ល្អ |
| | | | | | ៤.៣.២.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យមានការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ | ឈានមុខ |
| | | | | | ៤.៣.២.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីជំរុញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅលើកកម្ពស់គុណភាពអប់រំ។ | ឆ្នើម |

## ៣.៣.៥. ឯកទេសគ្រប់គ្រងរដ្ឋបាលអប់រំ

| លក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យរង | បរិយាយ | ភស្តុតាង | សូចនាករ | កម្រិតឋានៈវិជ្ជាជីវៈតាមសូចនាករ |
|---|---|---|---|---|---|
| ១. គុណវុឌ្ឍិ | ១.១. កម្រិតវប្បធម៌ | • សំដៅដល់កម្រិតអប់រំឧត្តមសិក្សាចុងក្រោយដែលបានបញ្ចប់សព្វគ្រប់ និងទទួលស្គាល់ជាលក្ខណៈជាតិ ឬអន្តរជាតិ រួមមានបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត ឬកម្រិតអប់រំដែលមានតម្លៃស្មើ។ កម្រិតអប់រំនេះមិនគិតតែទៅលើមុខវិជ្ជាឯកទេសទេ។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** កម្រិតបរិញ្ញាបត្រ<br>○ **អ្នកឯកទេសអប់រំឈានមុខ** កម្រិតបរិញ្ញាបត្រជាន់ខ្ពស់<br>○ **អ្នកឯកទេសអប់រំឆ្នើម** កម្រិតបណ្ឌិត | • សញ្ញាបត្រ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ | ១.១.១. កម្រិតបរិញ្ញាបត្រ | ល្អ |
| | | | | ១.១.២. កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | ឈានមុខ |
| | | | | ១.១.៣. កម្រិតបណ្ឌិត | ឆ្នើម |
| | ១.២. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | • សំដៅដល់ការចូលរៀនវគ្គបណ្តុះបណ្តាលក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំស្របតាមកម្រិតឋានៈវិជ្ជាជីវៈនីមួយៗ ដើម្បីបំពេញតម្រូវការការងារជាក់ស្តែងនៅកម្រិតអង្គភាព។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៦ ក្រេឌីត<br>○ **អ្នកឯកទេសអប់រំឈានមុខ** ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៩ ក្រេឌីត<br>○ **អ្នកឯកទេសអប់រំឆ្នើម** ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ១២ ក្រេឌីត | • ទិន្នន័យពី HRMIS | ១.៣.១. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៦ ក្រេឌីត | ល្អ |
| | | | | ១.៣.២. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៩ ក្រេឌីត | ឈានមុខ |
| | | | | ១.៣.៣. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ១២ ក្រេឌីត។ | ឆ្នើម |
| ២. បទពិសោធការងារ | ២.១. បទពិសោធបម្រើការជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡានៃ | • សំដៅដល់រយៈពេលជាក់លាក់ដែលបុគ្គលិកអប់រំបានបម្រើការជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងអង្គភាពថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និង | • លិខិតបង្គាប់ការ<br>• លិខិតឧទ្ទេសនាម<br>• ដីកា<br>• ប្រកាស | ២.១.១. បម្រើការងារជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាព | ល្អ |

| | | | | | |
|---|---|---|---|---|---|
| | រដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងអង្គភាពថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា | កីឡា។ រយៈពេលនេះ មិនរាប់បញ្ចូលពីរយៈពេលដែលបុគ្គលិកអប់រំព្យួរការងារទេ។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** បម្រើការងារជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា បានរយៈពេល ៣ ឆ្នាំ<br>○ **អ្នកឯកទេសអប់រំឈានមុខ** បម្រើការងារជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា បានរយៈពេល ៥ ឆ្នាំ<br>○ **អ្នកឯកទេសអប់រំផ្ដើម** បម្រើការងារជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា បានរយៈពេល ៧ ឆ្នាំ។ | • អនុក្រឹត្យ<br>• ព្រះរាជក្រឹត្យ។ | ថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា បានរយៈពេល ៣ ឆ្នាំ | |
| | | | | ២.១.២. បម្រើការងារជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា បានរយៈពេល ៥ ឆ្នាំ | ឈានមុខ |
| | | | | ២.១.៣. បម្រើការងារជាបុគ្គលិកអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពថ្នាក់កណ្ដាល នៃក្រសួងអប់រំ យុវជន និងកីឡា បានរយៈពេល ៧ ឆ្នាំ។ | ផ្ដើម |
| | ២.២. សមាជិកនៃសហគមន៍សិក្សាវិជ្ជាជីវៈ | • សំដៅដល់ការចូលជាសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈនៃបុគ្គលិកអប់រំ ដែលមានជំនាញឯកទេសដូចគ្នា និងធ្វើការរួមគ្នាដើម្បីចែករំលែកបទពិសោធ បច្ចេកទេស វិធីសាស្ត្រ របកគំហើញ ឬព័ត៌មានថ្មីៗ សំដៅពង្រឹងគុណភាពអប់រំ។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ចូលរួមជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួលសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈ | • លិខិតបង្គាប់ការ ឬប័ណ្ណសមាជិកភាព។ | ២.២.១. ចូលរួមជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ | ល្អ |
| | | | | ២.២.២. សម្របសម្រួលសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈ | ឈានមុខ |
| | | | | ២.២.៣. បង្កើតគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ក្នុងការដឹកនាំសកម្មភាពផ្សេងៗ របស់សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ | ផ្ដើម |

| | | | | | |
|---|---|---|---|---|---|
| | | ○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងការដឹកនាំសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ | | | |
| ៣. ស្នាដៃការងារ | ៣.១. ការបោះពុម្ពស្នាដៃស្រាវជ្រាវពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលអប់រំ | • សំដៅដល់ចំនួនស្នាដៃស្រាវជ្រាវពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលអប់រំ ដែលបានបោះពុម្ពនៅក្នុងកាលិកបត្រ ឬទស្សនាវដ្ដីស្រាវជ្រាវទទួលស្គាល់កម្រិតជាតិឬអន្តរជាតិ។ ស្នាដៃនេះរាប់បញ្ចូលទាំងស្នាដៃដែលមានលក្ខណៈបុគ្គល (ស្នាដៃទោល) ឬក្រុម (អ្នកស្រាវជ្រាវទី១)។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** បោះពុម្ពស្នាដៃស្រាវជ្រាវបានចំនួន ១ អត្ថបទ<br>○ **អ្នកឯកទេសអប់រំឈានមុខ** បោះពុម្ពស្នាដៃស្រាវជ្រាវបានចំនួន ៣ អត្ថបទ<br>○ **អ្នកឯកទេសអប់រំឆ្នើម** បោះពុម្ពស្នាដៃស្រាវជ្រាវបានចំនួន ៥ អត្ថបទ។ | • អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ ដែលបានបោះពុម្ពផ្សាយ។ | ៣.១.១. ចំនួន ១ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ | ល្អ |
| | | | | ៣.១.២. ចំនួន ៣ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ | ឈានមុខ |
| | | | | ៣.១.៣. ចំនួន ៥ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ។ | ឆ្នើម |
| | ៣.២. ការចែករំលែកចំណេះដឹង និងបទពិសោធ | • សំដៅដល់ចំនួនកម្មវិធី សិក្ខាសាលា សន្និសីទ ឬវគ្គបណ្តុះបណ្តាល ដែលបុគ្គលិកអប់រំ បានចូលរួមធ្វើបទបង្ហាញឬជាវាគ្មិនកិត្តិយស ដើម្បីចែករំលែកស្នាដៃ បទពិសោធការងារ ឬរបកគំហើញថ្មីដែលខ្លួនទទួលបានជោគជ័យក្នុងអាជីពការងាររបស់ខ្លួន។<br>• **បញ្ជាក់៖**សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ៥ កម្មវិធី<br>○ **អ្នកឯកទេសអប់រំឈានមុខ** បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ១០ កម្មវិធី<br>○ **អ្នកឯកទេសអប់រំឆ្នើម** បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ១៥ កម្មវិធី។ | • លិខិតឧទ្ទេសនាម ឬលិខិតអញ្ជើញ ដែលបញ្ជាក់ពីការធ្វើបទបង្ហាញ ឬជាវាគ្មិន។ | ៣.២.១. បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ៥ កម្មវិធី | ល្អ |
| | | | | ៣.២.២. បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ១០ កម្មវិធី | ឈានមុខ |
| | | | | ៣.២.៣. បានធ្វើបទបង្ហាញ ឬជាវាគ្មិនចែករំលែកបទពិសោធយ៉ាងតិចចំនួន ១៥ កម្មវិធី។ | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៣.៣. ស្នាដៃវិជ្ជាជីវៈផ្សេងទៀតដែលមានភស្តុតាងជាក់លាក់ | • សំដៅដល់ស្នាដៃ ឬជ័យលាភីណាមួយដែលបុគ្គលិកអប់រំទទួលបានក្នុងវិស័យអប់រំ និងមានការទទួលស្គាល់ពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឬរាជរដ្ឋាភិបាលកម្ពុជា ដូចជា៖<br>○ ស្នាដៃឆ្នើមក្នុងការរួមចំណែកក្នុងកម្មវិធីកំណែទម្រង់វិស័យអប់រំជាក់លាក់ណាមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>○ ការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួង ក្នុងការធានានិរន្តរភាពអប់រំក្នុងពេលមានវិបត្តិ។<br>• **បញ្ជាក់៖**<br>○ ស្នាដៃទាំងអស់មានតម្លៃពិន្ទុស្មើគ្នានៅក្នុងឋានៈវិជ្ជាជីវៈទាំងបី<br>○ ស្នាដៃដែលត្រូវបានវាយតម្លៃម្តងរួចហើយ មិនត្រូវបានរាប់បញ្ចូលក្នុងការវាយតម្លៃសម្រាប់ដំឡើងឋានៈវិជ្ជាជីវៈបន្ទាប់ទៀតទេ។ | • ពានរង្វាន់<br>• មេដាយការងារ<br>• បណ្ណសរសើរ។ | ៣.៣.១. ស្នាដៃដែល ទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬ រាជរដ្ឋាភិបាលកម្ពុជា។ | ឆ្នើម |
| ៤. សមត្ថភាពវិជ្ជាជីវៈ | ៤.១. វិជ្ជាសម្បទា | ភាសាបរទេស | ៤.១.១. ចំណេះដឹងភាសាបរទេស | • សំដៅដល់កម្រិតចំណេះដឹងភាសាបរទេសជាក់លាក់ណាមួយ ដែលបុគ្គលិកអប់រំបានសិក្សា។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** មានចំណេះដឹងភាសាបរទេសកម្រិតមធ្យម<br>○ **អ្នកឯកទេសអប់រំឈានមុខ** មានចំណេះដឹងភាសាបរទេសកម្រិតលើមធ្យម<br>○ **អ្នកឯកទេសអប់រំឆ្នើម** មានចំណេះដឹងប្រើប្រាស់ភាសាបរទេសកម្រិតខ្ពស់។ | • លទ្ធផលនៃការវាយតម្លៃកម្រិតអង្គភាព<br>**ចំណាំ៖** ការវាយតម្លៃកម្រិតអង្គភាពគួរពិចារណាលើ ភស្តុតាង ដូចជា លិខិតបញ្ជាក់ការសិក្សាភាសាបរទេស។ | ៤.១.១.១. កម្រិតមធ្យម | ល្អ |
| | | | | | | ៤.១.១.២. កម្រិតលើមធ្យម | ឈានមុខ |
| | | | | | | ៤.១.១.៣. កម្រិតខ្ពស់។ | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | គោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ | ៤.១.២. ចំណេះដឹងអំពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ និងកម្មវិធីសិក្សា | • សំដៅដល់ចំណេះដឹងអំពីចក្ខុវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឬគោលនយោបាយអប់រំចំណេះទូទៅ និងច្បាប់អប់រំ ដែលស្តែងចេញតាមរយៈសកម្មភាពដូចខាងក្រោម៖<br>○ ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ<br>○ ពណ៌នាបានពីយុទ្ធសាស្ត្រ របស់ក្រសួង ឬរាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យសម្រេចគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ<br>○ ចូលរួមផ្សព្វផ្សាយអំពីគោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋាន គតិយុត្តនានារបស់ក្រសួង។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ<br>○ **អ្នកឯកទេសអប់រំឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យ សម្រេចគោលដៅទាំងនោះ។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ។ | ៤.១.២.១. ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ល្អ |
| | | | | | | ៤.១.២.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ឈានមុខ |
| | | | | | | ៤.១.២.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ។ | ឆ្នើម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ការគ្រប់គ្រងរដ្ឋបាលអប់រំ | ៤.១.៣. ចំណេះដឹងពីការគ្រប់គ្រងរដ្ឋបាលអប់រំដែលមានប្រសិទ្ធភាព | • សំដៅដល់ចំណេះដឹងពីទ្រឹស្តីនិងបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ សំដៅធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន ព្រមលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ពណ៌នាបានពីទ្រឹស្តីនិងបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីទ្រឹស្តីនិងបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ<br>○ **អ្នកឯកទេសអប់រំឆ្នើម** ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ។ | ៤.១.៣.១. ពណ៌នាបានពីទ្រឹស្តីនិងបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ | ល្អ |
| | | | | | | ៤.១.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីទ្រឹស្តីនិងបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ | ឈានមុខ |
| | | | | | | ៤.១.៣.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ | ឆ្នើម |
| | ៤.២. បំណិនសម្បទា | ការគ្រប់គ្រងរដ្ឋបាលអប់រំ | ៤.២.១. បំណិនក្នុងការគ្រប់គ្រងរដ្ឋបាលអប់រំ | • សំដៅដល់បំណិនក្នុងការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** គ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំឆ្នាំ ។ | ៤.២.១.១. គ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ | ល្អ |
| | | | | | | ៤.២.១.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ | ឈានមុខ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ<br>○ **អ្នកឯកទេសអប់រំផ្តើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ | | ៤.២.១.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងបែងចែកធនធានក្នុងវិស័យអប់រំឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ | ផ្តើម |
| | | បច្ចេកវិទ្យាព័ត៌មានវិទ្យា | ៤.២.២. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ | • សំដៅដល់បំណិនក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា ដូចជា ការរៀបចំឧបករណ៍និងប្រមូលទិន្នន័យ និងការវិភាគទិន្នន័យជាដើម។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា<br>○ **អ្នកឯកទេសអប់រំផ្តើម** បង្កើតគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំ | ៤.២.២.១. ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា | ល្អ |
| | | | | | | ៤.២.២.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា | ឈានមុខ |
| | | | | | | ៤.២.២.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ វិភាគ និងអភិវឌ្ឍកម្មវិធីសិក្សា។ | ផ្តើម |

| | | | | | | |
|---|---|---|---|---|---|---|
| | ៤.៣. ចរិយាសម្បទា | ៤.៣.១. ការប្រតិបត្តិ ក្រមសីលធម៌វិជ្ជាជីវៈ | • សំដៅដល់ចរិយាសម្បទាក្នុងការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ តាមរយៈ៖<br>○ ការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ<br>○ ការពង្រឹងសាមគ្គីភាព<br>○ ការគោរពវិន័យការងារ<br>○ ការរក្សាការសម្ងាត់វិជ្ជាជីវៈ ភក្តីភាពចំពោះអង្គភាពផ្តល់តម្លៃដល់សហការី មិនមានការរើសអើង មិនប្រើហិង្សា និងសីលធម៌រស់នៅល្អ<br>○ ការប្រកាន់ខ្ជាប់នូវសុភវិនិច្ឆ័យ យុត្តិធម៌ តម្លាភាព និងការពិគ្រោះយោបល់ផ្អែកលើភស្តុតាងជាក់ស្តែង។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេសអប់រំល្អ** ប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួលសហការ និងគាំទ្រសហការីឱ្យប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ<br>○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីជំរុញការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ។ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំ។ | ៤.៣.១.១. ប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ | ល្អ |
| | | | | | ៤.៣.១.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ | ឈានមុខ |
| | | | | | ៤.៣.១.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីជំរុញការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ។ | ឆ្នើម |
| | | ៤.៣.២. ការប្តេជ្ញាចិត្ត | • សំដៅដល់ការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ។<br>• **បញ្ជាក់៖** សម្រាប់ឋានៈវិជ្ជាជីវៈទាំងបី៖<br>○ **អ្នកឯកទេស អប់រំល្អ** បង្ហាញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ<br>○ **អ្នកឯកទេសអប់រំឈានមុខ** សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យមានការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ | • លទ្ធផលវាយតម្លៃកម្រិតអង្គភាព ឬប្រចាំ | ៤.៣.២.១. បង្ហាញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ | ល្អ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ<br>○ **អ្នកឯកទេសអប់រំឆ្នើម** បង្កើតមធ្យោបាយឬវិធីសាស្ត្រ ប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីជំរុញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅលើកកម្ពស់គុណភាពអប់រំ។ | | ៤.៣.២.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យមានការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ | ឈានមុខ |
| | | | | | ៤.៣.២.៣. បង្កើតមធ្យោបាយឬវិធីសាស្ត្រ ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីជំរុញការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅលើកកម្ពស់គុណភាពអប់រំ។ | ឆ្នើម |

## ៤. ប្រព័ន្ធវាយតម្លៃ

### ៤.១. ការវាយតម្លៃ

ដើម្បីឈានដល់ការដំឡើងឋានៈវិជ្ជាជីវៈនៅក្នុងគន្លងអាជីពគ្រូបង្រៀន គ្រូ គណៈគ្រប់គ្រង និងអ្នកឯកទេសអប់រំ ត្រូវឆ្លងកាត់ការវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យទៅតាមគន្លងនីមួយៗដែលបានរៀបរាប់ខាងលើ។ នៅក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងនោះ គុណវុឌ្ឍិ បទពិសោធការងារ និងស្នាដៃការងារ មានលក្ខណៈសត្យានុម័ត និងមានភាពងាយស្រួលក្នុងការវាយតម្លៃផ្អែកតាមភស្តុតាងជាក់លាក់។ ដោយឡែក លទ្ធផលសិក្សារបស់សិស្ស និងសមត្ថភាពវិជ្ជាជីវៈ ទាមទារឱ្យមានការពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំ ដើម្បីទទួលបាននូវការវាយតម្លៃដ៏ត្រឹមត្រូវមួយ។ ដូច្នេះ យន្តការវាយតម្លៃត្រូវបានរៀបចំជាលក្ខណៈប្រព័ន្ធ ដែលក្នុងនោះមានការវាយតម្លៃជាប្រចាំ និងការវាយតម្លៃផ្ទៀងផ្ទាត់។ ដើម្បីធានាបាននូវភាពជាក់លាក់ ការវាយតម្លៃនេះ ត្រូវបានបែងចែកជាពីរគឺ កម្រិតអង្គភាព និងកម្រិតជាតិ។

ប្រព័ន្ធវាយតម្លៃ ត្រូវ៖

- សមស្របសម្រាប់ប្រើប្រាស់ក្នុងវិស័យអប់រំនៅកម្ពុជា
- គាំទ្រដំណើរការវាយតម្លៃ និងគណៈកម្មការវាយតម្លៃ
- ផ្អែកលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវដែលមានពីមុន
- ធានាថាគ្រប់ភាគីពាក់ព័ន្ធយល់ និងចូលរួមអនុវត្ត
- ពិនិត្យឡើងវិញជាប្រចាំ ដើម្បីឱ្យមានភាពងាយស្រួល និងសមស្របសម្រាប់អ្នកអនុវត្ត

ប្រព័ន្ធវាយតម្លៃ ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- អភិបាលកិច្ច
- គណនេយ្យភាព
- តម្លាភាព
- ឯករាជ្យភាព
- ទំនុកចិត្ត និងស្តង់ដា
- ការកែលម្អជាប្រចាំ
- សមមាត្រ
- ភាពបត់បែន នៃសេវាកម្ម
- កិច្ចសហការ

គណៈកម្មការវាយតម្លៃថ្នាក់ជាតិ

ដើម្បីគ្រប់គ្រង និងដឹកនាំការវាយតម្លៃនេះ គណៈកម្មការវាយតម្លៃកម្រិតជាតិមួយត្រូវបង្កើតដូចខាងក្រោម៖

➢ សមាសភាព

| | |
|---|---|
| ១. រដ្ឋលេខាធិការ | ជាប្រធាន |
| ២. អនុរដ្ឋលេខាធិការទទួលបន្ទុកបុគ្គលិក | ជាអនុប្រធាន |
| ៣. អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤. អគ្គាធិការនៃអគ្គាធិការដ្ឋាន | ជាអនុប្រធាន |
| ៥. ប្រធាននាយកដ្ឋានបុគ្គលិក | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៦. ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | ជាអនុប្រធាន |
| ៧. ប្រធាន ឬអនុប្រធាននាយកដ្ឋានកុមារតូច | ជាសមាជិក |
| ៨. ប្រធាន ឬអនុប្រធាននាយកដ្ឋានបឋមសិក្សា | ជាសមាជិក |
| ៩. ប្រធាន ឬអនុប្រធាននាយកដ្ឋានមធ្យមសិក្សា | ជាសមាជិក |
| ១០. ប្រធាន ឬអនុប្រធាននាយកដ្ឋានធានាគុណភាពអប់រំ | ជាសមាជិក |
| ១១. ប្រធាន ឬអនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | ជាសមាជិក |
| ១២. ប្រធាន ឬអនុប្រធាននាយកដ្ឋានគោលនយោបាយ | ជាសមាជិក |
| ១៣. ប្រធាន ឬអនុប្រធាននាយកដ្ឋានផែនការ | ជាសមាជិក |
| ១៤. ប្រធាន ឬអនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | ជាសមាជិក |
| ១៥. ប្រធាន ឬអនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | ជាសមាជិក |
| ១៦. ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ជាលេខាធិការ |

➢ តួនាទី និងភារកិច្ច

គណៈកម្មការវាយតម្លៃកម្រិតជាតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងដឹកនាំការងារទូទៅក្នុងដំណើរការវាយតម្លៃ
- រៀបចំផែនការ សម្របសម្រួល និងអភិវឌ្ឍសមត្ថភាពដល់គណៈកម្មការវាយតម្លៃកម្រិតជាតិ និងកម្រិតអង្គភាព ព្រមទាំងអ្នកពាក់ព័ន្ធ
- ពិនិត្យ និងសម្រេចលើបេក្ខភាពដែលត្រូវវាយតម្លៃ
- ផ្ទៀងផ្ទាត់ និងវាយតម្លៃបេក្ខជនដល់អង្គភាព
- រៀបចំការផ្តល់លាភការ

- កត់ត្រាលទ្ធផល និងទិន្នន័យពាក់ព័ន្ធទៅក្នុងប្រព័ន្ធHRMIS។

➢ **លេខាធិការដ្ឋាន**

ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលស្ថិតក្រោមឱវាទរបស់នាយកដ្ឋានបុគ្គលិក ដើរតួនាទីជាលេខាធិការដ្ឋាន និងជាសេនាធិការរបស់គណៈកម្មការវាយតម្លៃគន្លងអាជីពគ្រូបង្រៀនកម្រិតជាតិ។ ការិយាល័យនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការវាយតម្លៃរយៈពេលខ្លី និងរយៈពេលវែង សម្រាប់ការវាយតម្លៃគន្លងអាជីពគ្រូបង្រៀន
- រៀបចំផែនការ និងតម្រូវការថវិការយៈពេលខ្លី និងរយៈពេលវែង សម្រាប់ដំណើរការវាយតម្លៃគន្លងអាជីពគ្រូបង្រៀន
- រៀបចំផែនការ និងអភិវឌ្ឍសមត្ថភាពគណៈកម្មការវាយតម្លៃទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំពាក់ព័ន្ធ
- រៀបចំផែនការ និងការចុះទៅវាយតម្លៃដល់អង្គភាពសម្រាប់គណៈកម្មការវាយតម្លៃកម្រិតជាតិ
- រៀបចំលិខិតគតិយុត្តពាក់ព័ន្ធផ្សេងៗដូចជា សេចក្តីជូនដំណឹង និងការដំឡើងឋានៈវិជ្ជាជីវៈជាដើម
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ផ្តត់ផ្គង់សម្ភារ និងឯកសារពាក់ព័ន្ធ សម្រាប់ដំណើរការគណៈកម្មការវាយតម្លៃកម្រិតជាតិ
- កត់ត្រា និងធ្វើបច្ចុប្បន្នកម្មទិន្នន័យពាក់ព័ន្ធទៅក្នុង HRMIS
- រក្សាទុករបាយការណ៍ កំណត់ហេតុ និងឯកសារពាក់ព័ន្ធផ្សេងៗ
- បំពេញភារកិច្ចដទៃទៀត ដែលគណៈកម្មការវាយតម្លៃគន្លងអាជីពគ្រូបង្រៀនកម្រិតជាតិប្រគល់ជូន។

## ៤.១.១. កម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា

### *៤.១.១.១. គន្លងបង្រៀន*

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងបង្រៀន សំដៅដល់ការវាយតម្លៃគ្រូបង្រៀននៅកម្រិតគ្រឹះស្ថានសិក្សាចំណោះទូទៅ និងបច្ចេកទេស។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណងពិនិត្យវឌ្ឍនភាព គាំទ្រ និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ របស់គ្រូបង្រៀន តាមរយៈការកំណត់ចំណុចល្អ ចំណុចត្រូវកែលម្អ និងស្វែងរកដំណោះស្រាយសមស្របនិងទាន់ពេលវេលា ដើម្បីឱ្យគ្រូមានសមត្ថភាពស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ការវាយតម្លៃកម្រិតអង្គភាព បង្ហាញឱ្យគ្រូបង្រៀនដឹងថាខ្លួនសម្រេចលទ្ធផលការងារ និងផែនការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំកម្រិតណា ហើយបានត្រៀមខ្លួនរួចរាល់ហើយឬនៅក្នុងការដាក់ពាក្យស្នើសុំ

ទទួលការវាយតម្លៃចូលគន្លងអាជីព។ ការវាយតម្លៃនេះ ជាយន្តការកែលម្អការអនុវត្តការងាររបស់គ្រូបង្រៀនផ្អែកលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងតម្រូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយផ្សារភ្ជាប់នឹងយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍសាលារៀន។

ការវាយតម្លៃកម្រិតអង្គភាព ត្រូវធ្វើឡើងផ្អែកលើគោលការណ៍ ***អ្នកគ្រប់គ្រងវាយតម្លៃបុគ្គលិកនៅក្រោមឱវាទផ្ទាល់របស់ខ្លួន*** ។ ក្នុងន័យនេះគ្រូបង្រៀនត្រូវបានវាយតម្លៃដោយប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា។ ចំណែកឯប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា ត្រូវបានវាយតម្លៃដោយនាយក ឬនាយករងទទួលបន្ទុកការងារបច្ចេកទេស។ ការវាយតម្លៃនេះ ផ្តោតលើ៖

- លក្ខណៈវិនិច្ឆ័យទី៣៖ ស្នាដៃការងារជាក់លាក់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- លក្ខណៈវិនិច្ឆ័យទី៤៖ លក្ខណៈវិនិច្ឆ័យរងទាំងអស់នៅក្នុងលទ្ធផលសិក្សារបស់សិស្សដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- លក្ខណៈវិនិច្ឆ័យទី៥៖ សមត្ថភាពវិជ្ជាជីវៈជាក់លាក់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- សមិទ្ធផលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀនម្នាក់ៗ។

គណៈកម្មការវាយតម្លៃកម្រិតអង្គភាព

ដើម្បីគ្រប់គ្រង និងដឹកនាំការវាយតម្លៃនេះ គណៈកម្មការវាយតម្លៃមួយត្រូវបានបង្កើតនៅកម្រិតអង្គភាព ដូចខាងក្រោម៖

- ➢ សមាសភាព

ដើម្បីធានាសង្គតិភាព និងសុខដុមនីយកម្មនៅក្នុងការវាយតម្លៃបុគ្គលិកអប់រំ ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គ្រូបង្រៀន ត្រូវប្រើ ***គណៈកម្មការវាយតម្លៃការងារបុគ្គលិកសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ*** ដែលមានស្រាប់ ស្របតាមសេចក្តីណែនាំលេខ៣០ អយក.សជណ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃការងារបុគ្គលិក និងក្រុមប្រឹក្សាវិន័យសម្រាប់អង្គភាព និងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមាសភាព៖

- ○ នាយក ជាប្រធាន
- ○ នាយករង ជាអនុប្រធាន
- ○ ប្រធាន និងអនុប្រធានក្រុមបច្ចេកទេស ជាសមាជិក
- ○ មន្ត្រីទទួលបន្ទុកបុគ្គលិក ឬលេខាធិការ ជាសមាជិក

**កំណត់សម្គាល់៖** សមាសភាពគណៈកម្មវាយតម្លៃនេះ ប្រែប្រួលទៅតាមសេចក្តីណែនាំដែលមានសុពលភាព ពោលគឺបើមានសេចក្តីណែនាំថ្មី ដែលនិរាករណ៍លើសេចក្តីណែនាំខាងលើនេះ សមាសភាពគណៈកម្មការត្រូវកែសម្រួលតាមសេចក្តីណែនាំថ្មីនោះ។

- **តួនាទី និងភារកិច្ច**

គណៈកម្មការវាយតម្លៃកម្រិតអង្គភាព មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងដឹកនាំការងារទូទៅក្នុងដំណើរការវាយតម្លៃកម្រិតអង្គភាព
- គ្រប់គ្រង និងដឹកនាំការរៀបចំផែនការវាយតម្លៃកម្រិតអង្គភាព
- គ្រប់គ្រង និងដឹកនាំការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីពដល់គ្រូបង្រៀន
- គ្រប់គ្រង និងដឹកនាំការវាយតម្លៃការងារប្រចាំឆ្នាំរបស់គ្រូបង្រៀន។

- **ដំណើរការ**

ក្នុងការវាយតម្លៃកម្រិតអង្គភាព គ្រូបង្រៀនត្រូវឆ្លងកាត់ដំណើរការវាយតម្លៃជាបន្តបន្ទាប់ក្នុងរយៈពេលមួយឆ្នាំសិក្សាពេញ រួមមាន៖ ១) ការរៀបចំផែនការ ២) ការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព និង ៣) ការវាយតម្លៃ។ ដំណើរការវាយតម្លៃនេះ ត្រូវបញ្ចប់ឱ្យបានមុនពេលវិស្សមកាលមកដល់ ដើម្បីទុកលទ្ធភាពឱ្យគ្រូបង្រៀន មានពេលចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗក្នុងអំឡុងពេលវិស្សមកាល។

| ជំហាន | សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលវេលា | ឧបករណ៍ |
|---|---|---|---|---|
| ការរៀបចំផែនការ | - រៀបចំកិច្ចប្រជុំជាមួយបុគ្គលិកទាំងអស់ ដើម្បីកំណត់អ្នកវាយតម្លៃសម្រាប់គ្រូបង្រៀននីមួយៗនាដើមឆ្នាំសិក្សា។ | - គណៈកម្មការវាយតម្លៃ | - ខែវិច្ឆិកា នៃឆ្នាំសិក្សាថ្មី | |
| | - រៀបចំកិច្ចព្រមព្រៀងការងាររបស់ខ្លួនដែលមានផែនការការងារ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំ ព្រមទាំងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាស់ភាពជោគជ័យ។ | - គ្រូបង្រៀន និងអនុប្រធានក្រុមបច្ចេកទេស ឬអនុប្រធានមុខវិជ្ជា ជាមួយនឹងប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា<br>- ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា | - ខែវិច្ឆិកា នៃឆ្នាំសិក្សាថ្មី | - ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ |

| | | | | |
|---|---|---|---|---|
| | | ជាមួយនាយក ឬ នាយករងទទួលបន្ទុក | | |
| | - ផ្តល់អនុលោមភាពលើកិច្ចព្រមព្រៀងការងាររបស់គ្រូបង្រៀនម្នាក់ៗ | - ប្រធានគណៈកម្មការវាយតម្លៃ | | |
| ការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព | - ពិនិត្យវឌ្ឍនភាពការងារពាក់កណ្តាលឆ្នាំរបស់គ្រូបង្រៀនដែលខ្លួនទទួលបន្ទុកវាយតម្លៃធៀបទៅនឹងផែនការដែលបានដាក់ចេញនៅក្នុងកិច្ចព្រមព្រៀមប្រចាំឆ្នាំ។ | - គ្រូបង្រៀន និងអនុប្រធានក្រុមបច្ចេកទេស ឬអនុប្រធានមុខវិជ្ជា ជាមួយនឹងប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា<br>- ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា ជាមួយនាយក ឬនាយករងទទួលបន្ទុក | - ខែមីនា | - ទម្រង់វាយតម្លៃពាក់កណ្តាលឆ្នាំ |
| | - ប្រឹក្សាយោបល់ តម្រង់ទិស និងផ្តល់ការគាំទ្រទាន់ពេលវេលា ដើម្បីសម្រេចផែនការការងារ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដែលបានគ្រោងទុក។ | | - ខែមីនា | |
| ការវាយតម្លៃ | - សង្កេតការបង្រៀនរបស់គ្រូដែលខ្លួនត្រូវវាយតម្លៃ។ ការសង្កេតថ្នាក់រៀននេះត្រូវធ្វើឡើងជាមួយនឹងយន្តការអធិការកិច្ចផ្ទៃក្នុងរបស់សាលារៀន។ | - គណៈកម្មការវាយតម្លៃ | - ខែឧសភា | ឧបករណ៍ដែលមានស្រាប់នៅក្នុងយន្តការអធិការកិច្ចផ្ទៃក្នុង |
| | - ធ្វើស្វ័យវាយតម្លៃ ដោយផ្អែកលើសមិទ្ធផលការងារ និងការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ។ | - គ្រូបង្រៀន<br>- អនុប្រធាន និងអនុប្រធានក្រុមបច្ចេកទេស ឬអនុប្រធានមុខវិជ្ជា<br>- ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា | - ខែសីហា | - ទម្រង់ស្វ័យវាយតម្លៃ |

| | | | | |
|---|---|---|---|---|
| | - ប្រមូលព័ត៌មាន៣៦០ ដឺក្រេ ពីអ្នកជុំវិញចំនួនបីនាក់ អំពីចរិតលក្ខណៈ និងក្រមសីលធម៌ របស់គ្រូបង្រៀន ដែលត្រូវវាយតម្លៃនោះ។ ការផ្តល់ព័ត៌មាននេះ ត្រូវធ្វើឡើងដោយសម្ងាត់។ | - ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជាសម្រាប់គ្រូបង្រៀន និងអនុប្រធានក្រុមបច្ចេកទេស ឬអនុប្រធានមុខវិជ្ជា<br>- នាយក ឬនាយករងទទួលបន្ទុកសម្រាប់ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា | - ខែសីហា | |
| | - វាយតម្លៃលើការអនុវត្តកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់គ្រូបង្រៀន ដោយផ្អែកលើសមិទ្ធផលការងារការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារជាប្រឆ្នាំ  លទ្ធផលនៃការវាយម្លៃខ្លួនឯងរបស់គ្រូបង្រៀននោះ និងព័ត៌មាន៣៦០ដឺក្រេ។ | - ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជាសម្រាប់គ្រូបង្រៀន និងអនុប្រធានក្រុមបច្ចេកទេស ឬអនុប្រធានមុខវិជ្ជា<br>- នាយក ឬនាយករងទទួលបន្ទុកសម្រាប់ប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា | - ខែសីហា | ទម្រង់វាយតម្លៃការងារចុងឆ្នាំ |
| | - ផ្តល់ការប្រឹក្សាលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការដាក់ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន។ | | | |
| | - ពិនិត្យ និងអនុម័តលើលទ្ធផលវាយតម្លៃប្រចាំឆ្នាំរបស់គ្រូបង្រៀនម្នាក់ៗ | - គណៈកម្មការវាយតម្លៃ | - ខែកញ្ញា | |

| | | | | |
|---|---|---|---|---|
| | - បញ្ជូនលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំទៅតាមឋានានុក្រម។ | - គណៈកម្មការវាយតម្លៃ | - ខែកញ្ញា | |

### ៤.១.១.២. គន្លងគ្រប់គ្រង

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង សំដៅដល់ការវាយតម្លៃនាយក និងនាយករង នៅកម្រិតគ្រឹស្ថានសិក្សាចំណេះទូទៅ និងបច្ចេកទេស។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណងពិនិត្យវឌ្ឍនភាព គាំទ្រ និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ របស់នាយក ឬនាយករង តាមរយៈការកំណត់ចំណុចល្អ ចំណុចត្រូវកែលម្អ និងស្វែងរកដំណោះស្រាយសមស្រប និងទាន់ពេលវេលា ដើម្បីឱ្យពួកគាត់មានសមត្ថភាពស្របតាមស្តង់ដានាយក។

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង បង្ហាញឱ្យនាយក ឬនាយករងដឹងថាខ្លួនសម្រេចលទ្ធផលការងារ និងផែនការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំកម្រិតណា ហើយបានត្រៀមខ្លួនរួចរាល់ហើយឬនៅក្នុងការដាក់ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីព។ ការវាយតម្លៃនេះ ជាយន្តការកែលម្អការអនុវត្តការងាររបស់នាយក ឬនាយករង ផ្អែកលើស្តង់ដានាយក និងតម្រូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយផ្សារភ្ជាប់នឹងយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍសាលារៀន។

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង ត្រូវធ្វើឡើងផ្អែកលើគោលការណ៍ ***អ្នកគ្រប់គ្រងវាយតម្លៃបុគ្គលិកនៅក្រោមឱវាទផ្ទាល់របស់ខ្លួន*** ។ ក្នុងន័យនេះ នាយរង ត្រូវបានវាយតម្លៃដោយនាយក។ ចំណែកឯនាយក ត្រូវបានវាយតម្លៃដោយប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ។ សម្រាប់ករណីដោយឡែក អ្នកវាយតម្លៃ នឹងត្រូវបានចាត់តាំងដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត។ ការវាយតម្លៃនេះ ផ្តោតលើ៖

- លក្ខណៈវិនិច្ឆ័យទី៣៖ ស្នាដៃការងារជាក់លាក់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- លក្ខណៈវិនិច្ឆ័យទី៤៖ លក្ខណៈវិនិច្ឆ័យរងទាំងអស់នៅក្នុងលទ្ធផលសិក្សារបស់សិស្សដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- លក្ខណៈវិនិច្ឆ័យទី៥៖ សមត្ថភាពវិជ្ជាជីវៈជាក់លាក់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- សមិទ្ធផលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គណៈគ្រប់គ្រងម្នាក់ៗ។

#### គណៈកម្មការវាយតម្លៃ

ដើម្បីគ្រប់គ្រង និងដឹកនាំការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង គណៈកម្មការវាយតម្លៃមួយត្រូវបានបង្កើតនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

- សមាសភាព

ដើម្បីធានាសង្គតិភាព និងសុខដុមនីយកម្មនៅក្នុងការវាយតម្លៃបុគ្គលិកអប់រំ ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង ត្រូវប្រើ ***គណៈកម្មការវាយតម្លៃការងារបុគ្គលិកសម្រាប់អង្គភាពរដ្ឋបាល*** ដែលមានស្រាប់ ស្របតាមសេចក្តីណែនាំលេខ៣០ អយក.សជណ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃការងារបុគ្គលិកនិងក្រុមប្រឹក្សាវិន័យសម្រាប់អង្គភាព និងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡាមានសមាសភាព៖

- ប្រធានការិយាល័យ ជាប្រធាន
- អនុប្រធានការិយាល័យ ជាអនុប្រធាន
- មន្ត្រីទទួលបន្ទុកការងារបុគ្គលិក ជាលេខាធិការ
- ប្រធានផ្នែកទាំងអស់ ជាសមាជិក

**កំណត់សម្គាល់៖** សមាសភាពគណៈកម្មការវាយតម្លៃនេះ ប្រែប្រួលទៅតាមសេចក្តីណែនាំដែលមានសុពលភាព ពោលគឺបើមានសេចក្តីណែនាំថ្មី ដែលនិរាករណ៍លើសេចក្តីណែនាំខាងលើនេះសមាសភាពគណៈកម្មការត្រូវកែសម្រួលតាមសេចក្តីណែនាំថ្មីនោះ។

- តួនាទី និងភារកិច្ច

គណៈកម្មការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងដឹកនាំការងារទូទៅក្នុងដំណើរការវាយតម្លៃគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅនៅក្រោមឱវាទ
- គ្រប់គ្រង និងដឹកនាំការរៀបចំផែនការវាយតម្លៃគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅនៅក្រោមឱវាទ
- គ្រប់គ្រងនិងដឹកនាំការប្រឹក្សាយោបល់តម្រង់ទិសនិងគាំទ្រការអភិវឌ្ឍអាជីពដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅនៅក្រោមឱវាទ
- គ្រប់គ្រង និងដឹកនាំការវាយតម្លៃការងារប្រចាំឆ្នាំរបស់គណៈគ្រប់គ្រងគ្រឹស្ថានសិក្សាចំណេះទូទៅនៅក្រោមឱវាទ។

- ដំណើរការ

ក្នុងការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងគ្រប់គ្រង នាយក និងនាយករងត្រូវឆ្លងកាត់ដំណើរការវាយតម្លៃជាបន្តបន្ទាប់ក្នុងរយៈពេលមួយឆ្នាំសិក្សាពេញរួមមាន៖ ១) ការរៀបចំផែនការ ២) ការប្រឹក្សា យោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព និង ៣) ការវាយតម្លៃ។ ដំណើរការវាយតម្លៃនេះត្រូវបញ្ចប់ឱ្យបានមុនពេលវិស្សមកាលមកដល់ ដើម្បីទុកលទ្ធភាពឱ្យនាយក និងនាយករង មានពេលចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗក្នុងអំឡុងពេលវិស្សមកាល។

| ជំហាន | សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលវេលា | ឧបករណ៍ |
|---|---|---|---|---|
| ការរៀបចំផែនការ | - រៀបចំកិច្ចប្រជុំ ដើម្បីកំណត់អ្នកវាយតម្លៃសម្រាប់នាយក ឬនាយករងនីមួយៗនាដើមឆ្នាំសិក្សា។ | - គណៈកម្មការវាយតម្លៃកម្រិតអង្គភាព | - ខែវិច្ឆិកា នៃឆ្នាំសិក្សាថ្មី | |
| | - រៀបចំកិច្ចព្រមព្រៀងការងាររបស់ខ្លួន ដែលមានផែនការការងារ□ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំ ព្រមទាំងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាស់ភាពជោគជ័យ។ | - ប្រធានការិយាល័យ និងនាយក<br>- នាយក និងនាយករង | - ខែវិច្ឆិកា នៃឆ្នាំសិក្សាថ្មី | - ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ |
| | - ផ្តល់អនុលោមភាពលើកិច្ចព្រមព្រៀងការងាររបស់គ្រូបង្រៀនម្នាក់ៗ | - ប្រធានគណៈកម្មការវាយតម្លៃកម្រិតការិយាល័យ | | |
| ការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព | - ពិនិត្យវឌ្ឍនភាពការងារពាក់កណ្តាលឆ្នាំរបស់នាយក ឬនាយករង ដែលខ្លួនទទួលបន្ទុកវាយតម្លៃ ធៀបទៅនឹងផែនការដែលបានដាក់ចេញនៅក្នុងកិច្ចព្រមព្រៀមប្រចាំ។ | - ប្រធានការិយាល័យ និងនាយក<br>- នាយក និងនាយករង | - ខែមីនា | - ទម្រង់វាយតម្លៃពាក់កណ្តាលឆ្នាំ |
| | - ប្រឹក្សាយោបល់ តម្រង់ទិស និងផ្តល់ការគាំទ្រទាន់ពេលវេលា ដើម្បីសម្រេចផែនការការងារ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដែលបានគ្រោងទុក។ | - ប្រធានការិយាល័យសម្រាប់នាយក<br>- នាយក សម្រាប់នាយករង | - ខែមីនា | |
| ការវាយតម្លៃ | - ធ្វើស្វ័យវាយតម្លៃដោយផ្អែកលើសមិទ្ធផលការងារ និងការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារជាប្រចាំ។ | - នាយក និងនាយករង | - ខែសីហា | - ទម្រង់ស្វ័យវាយតម្លៃ |

| | | | | |
|---|---|---|---|---|
| | - ប្រមូលព័ត៌មាន៣៦០ដឺក្រេ ពីអ្នកជុំវិញចំនួនបីនាក់ អំពីចរិតលក្ខណៈ និងក្រមសីលធម៌របស់នាយក ឬនាយករង ដែលត្រូវវាយតម្លៃនោះ។ ការផ្តល់ព័ត៌មាននេះ ត្រូវធ្វើឡើងដោយសម្ងាត់។ | - ប្រធានការិយាល័យ សម្រាប់នាយក<br>- នាយក សម្រាប់នាយករង | - ខែសីហា | |
| | - វាយតម្លៃលើការអនុវត្តកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់នាយក ឬនាយករង ដោយផ្អែកលើសមិទ្ធផលការងារ ការអភិវឌ្ឍវិជ្ជាជីវៈ ដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំលទ្ធផលនៃការវាយម្លៃខ្លួនឯងរបស់នាយក ឬនាយករងនោះ និងព័ត៌មាន៣៦០ដឺក្រេ។ | - ប្រធានការិយាល័យ សម្រាប់នាយក<br>- នាយក សម្រាប់នាយករង | - ខែសីហា | ទម្រង់វាយតម្លៃការងារចុងឆ្នាំ |
| | - ផ្តល់ការប្រឹក្សាលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការដាក់ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីពគ្រប់គ្រង។ | - ប្រធានការិយាល័យ សម្រាប់នាយក<br>- នាយក សម្រាប់នាយករង | - ខែសីហា | |
| | - ពិនិត្យ និងអនុម័តលើលទ្ធផលវាយតម្លៃប្រចាំឆ្នាំរបស់នាយក ឬនាយករងម្នាក់ៗ។ | - គណៈកម្មការវាយតម្លៃ | - ខែកញ្ញា | |
| | - បញ្ជូនលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំទៅតាមឋានានុក្រម។ | - គណៈកម្មការវាយតម្លៃ | - ខែកញ្ញា | |

### ៤.១.១.៣. គន្លងឯកទេសអប់រំ

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ សំដៅដល់ការវាយតម្លៃបុគ្គលិកអប់រំនៅគ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួងរហូតដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ លើកលែងតែគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សា ដែលមានលក្ខខណ្ឌដោយឡែក។

ការវាយតម្លៃនេះ ត្រូវធ្វើឡើងរៀងរាល់ឆ្នាំ ក្នុងគោលបំណងពិនិត្យវឌ្ឍនភាព គាំទ្រ និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ របស់បុគ្គលិកអប់រំតាមរយៈការកំណត់ចំណុចល្អ ចំណុចត្រូវកែលម្អ និងស្វែងរកដំណោះស្រាយសមស្រប និងទាន់ពេលវេលា ដើម្បីឱ្យពួកគាត់មានសមត្ថភាពបំពេញការងារប្រកបដោយប្រសិទ្ធភាព។

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ បង្ហាញឱ្យបុគ្គលិកអប់រំម្នាក់ៗដឹងថាខ្លួនសម្រេចលទ្ធផលការងារ និងផែនការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំកម្រិតណា ហើយបានត្រៀមខ្លួនរួចរាល់ហើយឬនៅក្នុងការដាក់ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីព។ ការវាយតម្លៃនេះ ក៏ជាយន្តការកែលម្អការអនុវត្តការងាររបស់បុគ្គលិកអប់រំ ផ្អែកតាមផែនការយុទ្ធសាស្ត្ររបស់អង្គភាព ក៏ដូចជាផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ។

ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ ត្រូវធ្វើឡើងផ្អែកលើគោលការណ៍ ***អ្នកគ្រប់គ្រងវាយតម្លៃបុគ្គលិកនៅក្រោមឱវាទផ្ទាល់របស់ខ្លួន*** ។ ក្នុងន័យនេះ ការវាយតម្លៃ ត្រូវបានកំណត់ដូចខាងក្រោម៖

| **ថ្នាក់ជាតិ** | |
|---|---|
| អ្នកវាយតម្លៃ | អ្នកដែលត្រូវបានវាយតម្លៃ |
| - អនុរដ្ឋលេខាធិការទទួលបន្ទុក | - អគ្គនាយក |
| - អគ្គនាយក | - អគ្គនាយករង |
| - អគ្គនាយករង | - ប្រធាននាយកដ្ឋាន |
| - ប្រធាននាយកដ្ឋាន ឬប្រធានអង្គភាពឋានៈស្មើប្រធាននាយកដ្ឋាន | - អនុប្រធាននាយកដ្ឋាន ឬអនុប្រធានអង្គភាពឋានៈស្មើអនុប្រធាននាយកដ្ឋាន |
| - អនុប្រធាននាយកដ្ឋាន ឬអនុប្រធានអង្គភាពឋានៈស្មើអនុប្រធាននាយកដ្ឋាន | - ប្រធានការិយាល័យ ឬប្រធានផ្នែកឋានៈស្មើប្រធានការិយាល័យ |
| - ប្រធានការិយាល័យ ឬប្រធានផ្នែកឋានៈស្មើប្រធានការិយាល័យ | - អនុប្រធានការិយាល័យ<br>- អនុប្រធានផ្នែកក្រោមឱវាទ<br>- មន្ត្រី |
| **ថ្នាក់ក្រោមជាតិ** | |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ឬប្រធាននាយកដ្ឋានបុគ្គលិក<br>- នាយករដ្ឋបាលសាលារាជធានី ខេត្ត | - ប្រធានមន្ទីរ |
| - ប្រធានមន្ទីរ | - អនុប្រធានមន្ទីរ |
| - អនុប្រធានមន្ទីរ | - ប្រធានការិយាល័យក្រោមឱវាទ |
| - ប្រធានការិយាល័យក្រោមឱវាទមន្ទីរ | - អនុប្រធានការិយាល័យ<br>- ប្រធានផ្នែក<br>- មន្ត្រីក្រោមឱវាទ |

| | |
|---|---|
| - អភិបាល ក្រុង ស្រុក ខណ្ឌ ឬនាយករដ្ឋបាល ក្រុង ស្រុក ខណ្ឌ<br>- ប្រធានមន្ទីរ | - ប្រធានការិយាល័យ អយក |
| - ប្រធានការិយាល័យ អយក | - អនុប្រធានការិយាល័យ<br>- ប្រធានផ្នែកក្រោមឱវាទការិយាល័យ<br>- មន្ត្រី |

ការវាយតម្លៃនេះ ផ្តោតលើ៖

- លក្ខណៈវិនិច្ឆ័យទី៣៖ ស្នាដៃការងារជាក់លាក់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- លក្ខណៈវិនិច្ឆ័យទី៤៖ សមត្ថភាពវិជ្ជាជីវៈជាក់លាក់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ
- សមិទ្ធផលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់បុគ្គលិកអប់រំម្នាក់ៗ។

គណៈកម្មការវាយតម្លៃ

ដើម្បីគ្រប់គ្រង និងដឹកនាំការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ គណៈកម្មការវាយតម្លៃមួយត្រូវបានបង្កើតនៅកម្រិតអង្គភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- សមាសភាព

ដើម្បីធានាសង្គតិភាព និងសុខដុមនីយកម្មនៅក្នុងការវាយតម្លៃបុគ្គលិកអប់រំ ការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ ត្រូវប្រើ ***គណៈកម្មការវាយតម្លៃការងារបុគ្គលិកសម្រាប់អង្គភាពរដ្ឋបាល*** ដែលមានស្រាប់ ស្របតាមសេចក្តីណែនាំលេខ៣០ អយក.សជណ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃការងារបុគ្គលិក និងក្រុមប្រឹក្សាវិន័យសម្រាប់អង្គភាព និងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធានអង្គភាព ជាប្រធាន
- អនុប្រធានអង្គភាព ជាអនុប្រធាន
- ប្រធាន និងអនុប្រធានការិយាល័យ ជាសមាជិក
- មន្ត្រីទទួលបន្ទុកការងារបុគ្គលិក ជាលេខាធិការ
- ប្រធានផ្នែកទាំងអស់ (អង្គភាពមិនមានការិយាល័យ) ជាសមាជិក

**កំណត់សម្គាល់៖** សមាសភាពគណៈកម្មវាយតម្លៃនេះ ប្រែប្រួលទៅតាមសេចក្តីណែនាំដែលមានសុពលភាព ពោលគឺបើមានសេចក្តីណែនាំថ្មី ដែលនិរាករណ៍លើសេចក្តីណែនាំខាងលើនេះ សមាសភាពគណៈកម្មការត្រូវកែសម្រួលតាមសេចក្តីណែនាំថ្មីនោះ។

ដោយឡែកសម្រាប់ការវាយតម្លៃអគ្គនាយក គណៈកម្មការមួយត្រូវបានបង្កើតដែលមានសមាសភាពដូចខាងក្រោម៖

- ○ រដ្ឋលេខាធិការ ជាប្រធាន
- ○ អនុរដ្ឋលេខាធិការទទួលបន្ទុកការងារបុគ្គលិក ជាអនុប្រធាន
- ○ អនុរដ្ឋលេខាធិការទាំងអស់ ជាសមាជិក
- ○ ប្រធាននាយកដ្ឋានបុគ្គលិក ជាលេខាធិការ

➢ **តួនាទី និងភារកិច្ច**

គណៈកម្មការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងដឹកនាំការងារទូទៅក្នុងដំណើរការវាយតម្លៃបុគ្គលិកអប់រំក្នុងអង្គភាព
- គ្រប់គ្រង និងដឹកនាំការរៀបចំផែនការវាយតម្លៃបុគ្គលិកអប់រំក្នុងអង្គភាព
- គ្រប់គ្រង និងដឹកនាំការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីពដល់បុគ្គលិកអប់រំក្នុងអង្គភាព
- គ្រប់គ្រង និងដឹកនាំការវាយតម្លៃការងារប្រចាំឆ្នាំរបស់បុគ្គលិកអប់រំក្នុងអង្គភាព។

➢ **ដំណើរការ**

ក្នុងការវាយតម្លៃកម្រិតអង្គភាពសម្រាប់គន្លងឯកទេសអប់រំ បុគ្គលិកអប់រំត្រូវឆ្លងកាត់ដំណើរការវាយតម្លៃជាបន្តបន្ទាប់ក្នុងរយៈពេលមួយឆ្នាំ រួមមាន៖ ១) ការរៀបចំផែនការ ២) ការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព និង ៣) ការវាយតម្លៃ។

| ជំហាន | សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលវេលា | ឧបករណ៍ |
|---|---|---|---|---|
| ការរៀបចំផែនការ | - រៀបចំកិច្ចប្រជុំ ដើម្បីកំណត់អ្នកវាយតម្លៃសម្រាប់បុគ្គលិកអប់រំ នីមួយៗ។ | - គណៈកម្មការវាយតម្លៃប្រចាំអង្គភាពនីមួយៗ | - ខែវិច្ឆិកា | |
| | - រៀបចំកិច្ចព្រមព្រៀងការងាររបស់ខ្លួន ដែលមានផែនការការងារ□ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំ ព្រមទាំងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាស់ភាពជោគជ័យ។ | - អ្នកគ្រប់គ្រងផ្ទាល់ និងបុគ្គលិកអប់រំក្រោមឱវាទ | - ខែវិច្ឆិកា | - ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ |
| | - ផ្តល់អនុលោមភាពលើកិច្ចព្រមព្រៀងការងាររបស់បុគ្គលិកអប់រំម្នាក់ៗ។ | - គណៈកម្មការវាយតម្លៃប្រចាំអង្គភាពនីមួយៗ | | |

| | | | | |
|---|---|---|---|---|
| ការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព | - ពិនិត្យវឌ្ឍនភាពការងារពាក់កណ្តាលឆ្នាំរបស់បុគ្គលិកអប់រំដែលខ្លួនទទួលបន្ទុកវាយតម្លៃធៀបទៅនឹងផែនការដែលបានដាក់ចេញនៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ។ | - អ្នកគ្រប់គ្រងផ្ទាល់ និងបុគ្គលិកអប់រំក្រោមឱវាទ | - ខែមីនា | - ទម្រង់វាយតម្លៃពាក់កណ្តាលឆ្នាំ |
| | - ប្រឹក្សាយោបល់ តម្រង់ទិស និងផ្តល់ការគាំទ្រទាន់ពេលវេលា ដើម្បីសម្រេចផែនការការងារ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដែលបានគ្រោងទុក។ | - អ្នកគ្រប់គ្រងផ្ទាល់ | - ខែមីនា | |
| ការវាយតម្លៃ | - ធ្វើស្វ័យវាយតម្លៃ ដោយផ្អែកលើសមិទ្ធផលការងារ និងការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារជាប្រចាំ។ | - បុគ្គលិកអប់រំ | - ខែសីហា | - ទម្រង់ស្វ័យវាយតម្លៃ |
| | - ប្រមូលព័ត៌មាន៣៦០ដឺក្រេពីអ្នកជុំវិញចំនួនបីនាក់ អំពីចរិតលក្ខណៈ និងក្រមសីលធម៌ របស់បុគ្គលិកអប់រំ ដែលត្រូវវាយតម្លៃនោះ។ ការផ្តល់ព័ត៌មាននេះ ត្រូវធ្វើឡើងដោយសម្ងាត់។ | - អ្នកគ្រប់គ្រងផ្ទាល់ | - ខែសីហា | ទម្រង់ពត៌មាន៣៦០ដឺក្រេ |
| | - វាយតម្លៃលើការអនុវត្តកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់បុគ្គលិកអប់រំ ដោយផ្អែកលើសមិទ្ធផលការងារ ការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំលទ្ធផលនៃការវាយម្លៃ | - អ្នកគ្រប់គ្រងផ្ទាល់ | - ខែសីហា | ទម្រង់វាយតម្លៃការងារចុងឆ្នាំ |

| | | | | |
|---|---|---|---|---|
| | ខ្លួនឯងរបស់បុគ្គលិកអប់រំនោះ និងព័ត៌មាន ៣៦០ដឺក្រេ។ | | | |
| | - ផ្តល់ការប្រឹក្សាលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការដាក់ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីព។ | - អ្នកគ្រប់គ្រងផ្ទាល់ | - ខែសីហា | |
| | - ពិនិត្យ និងអនុម័តលើលទ្ធផលវាយតម្លៃប្រចាំឆ្នាំរបស់បុគ្គលិកអប់រំម្នាក់ៗ។ | - គណៈកម្មការវាយតម្លៃប្រចាំអង្គភាពនីមួយៗ | - ខែកញ្ញា | |
| | - បញ្ជូនលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំទៅតាមឋានានុក្រម។ | - គណៈកម្មការវាយតម្លៃប្រចាំអង្គភាពនីមួយៗ | - ខែកញ្ញា | |

### ៤.១.២. កម្រិតជាតិ

ការវាយតម្លៃកម្រិតជាតិ គឺជាដំណើរការវាយតម្លៃដើម្បីដំឡើងឋានៈវិជ្ជាជីវៈសម្រាប់គន្លងទាំងបីនៅក្នុងគន្លងអាជីពគ្រូបង្រៀន និងត្រូវធ្វើឡើងបន្ទាប់ពីទទួលបានការដាក់ពាក្យស្នើសុំពីបេក្ខជនតាមរយៈ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឬអង្គភាពសាមី។ ការវាយតម្លៃនេះ ធ្វើឡើងដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ ថាតើបេក្ខភាពដែលបានសម្រេចនិងបញ្ជូនតាមឋានានុក្រម បានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យសម្រាប់ការឡើងឋានៈវិជ្ជាជីវៈសម្រាប់គន្លងទាំងបីនៅក្នុងគន្លងអាជីពគ្រូបង្រៀនដែរឬទេ។

ការវាយតម្លៃកម្រិតជាតិ ត្រូវធ្វើឡើងដោយគណៈកម្មការវាយតម្លៃកម្រិតជាតិ ក្រោមការសម្របសម្រួល និងរៀបចំដោយលេខាធិការដ្ឋាន។ ការវាយតម្លៃនេះ ផ្តោតលើលក្ខណៈវិនិច្ឆ័យទាំងប្រាំសម្រាប់គន្លងបង្រៀន និងគន្លងគ្រប់គ្រង និងលក្ខណៈវិនិច្ឆ័យទាំងបួនសម្រាប់គន្លងឯកទេសអប់រំ។

- **សមាសភាព**

  សមាសភាពគណៈកម្មការវាយតម្លៃថ្នាក់ជាតិ ត្រូវបានកំណត់ដូចនៅក្នុងចំណុច ៤.១ ខាងលើ។

- **តួនាទី និងភារកិច្ច**

  តួនាទី និងភារកិច្ចរបស់គណៈកម្មការនេះ ត្រូវបានកំណត់ដូចនៅក្នុងចំណុច ៤.១ ខាងលើ។

- **ដំណើរការ**

| ជំហាន | សកម្មភាព | ពេលវេលា | ឧបករណ៍ |
|---|---|---|---|
| - ការពិនិត្យ និងសម្រេចលើបញ្ជីបេក្ខភាព | - ទាញយករបាយការណ៍ពាក់ព័ន្ធនឹងបេក្ខជនដែលត្រូវវាយតម្លៃពី HRMIS | ខែវិច្ឆិកា ឆ្នាំសិក្សាបន្ទាប់ | |

| | | | |
|---|---|---|---|
| | - ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខភាពដែលបានស្នើឡើងតាមរយៈមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឬ អង្គភាពសាមី ដោយផ្អែកលើរបាយការណ៍ពី HRMIS។ | | |
| - ការផ្ទៀងផ្ទាត់ និងវាយតម្លៃ | - រៀបចំផែនការ និងជូនដំណឹងដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឬ អង្គភាពសាមី ពីកាលបរិច្ឆេទចុះទៅផ្ទៀងផ្ទាត់ និងវាយតម្លៃដល់អង្គភាព | ខែវិច្ឆិកា | |
| | - ផ្ទៀងផ្ទាត់ និងវាយតម្លៃដល់អង្គភាព ដោយផ្តោតលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់<br>- សម្គាល់៖<br>○ គ្រូបង្រៀន ត្រូវផ្តល់បទបង្ហាញខ្លីៗអំពីប្រវត្តិការងាររបស់ខ្លួន និងហេតុផលដែលបង្ហាញថាខ្លួនបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យ និងឯកសារភស្តុតាងពាក់ព័ន្ធ។<br>○ សមាជិកគណៈកម្មការវាយតម្លៃកម្រិតជាតិមានតួនាទីសួរសំណួរទៅបេក្ខជនផ្អែកលើបទបង្ហាញខាងលើ របាយការណ៍ HRMIS និងឯកសារ ភស្តុតាងពាក់ព័ន្ធ។<br>○ គ្រូបង្រៀន មានតួនាទីឆ្លើយតបនឹងសំណួរផ្សេងៗ និងបង្ហាញភស្តុតាងឱ្យបានក្បោះក្បាយ និងគ្រប់គ្រាន់។ | ខែធ្នូ | ឧបករណ៍វាយតម្លៃគន្លងអាជីពសម្រាប់គ្រូបង្រៀន |
| | - ពិនិត្យ ផ្ទៀតផ្ទាត់ និងដាក់ពិន្ទុតាមលក្ខណៈវិនិច្ឆ័យ និងលក្ខណៈវិនិច្ឆ័យរងនីមួយៗ ដូចខាងក្រោម៖<br>○ សម្រាប់គន្លងបង្រៀន និងគន្លងគ្រប់គ្រង៖ ***គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ លទ្ធផលសិក្សារបស់សិស្ស*** និង ***សមត្ថភាពវិជ្ជាជីវៈ*** | | |

| | | | |
|---|---|---|---|
| | ○ សម្រាប់គន្លងឯកទេសអប់រំ៖ ***គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ*** និង ***សមត្ថភាពវិជ្ជាជីវៈ***។ | | |
| - ការបូកសរុប និង ប្រកាសលទ្ធផល | - បូកសរុបពិន្ទុ និងធ្វើចំណាត់ថ្នាក់បេក្ខជនទូទាំងប្រទេស | ខែមករា | |
| | - ពិនិត្យ និងសម្រេចជ្រើសរើសបេក្ខជនដែលត្រូវដំឡើងឋានៈវិជ្ជាជីវៈ | ខែកុម្ភៈ | |
| | ប្រកាសលទ្ធផលផ្លូវការ<br>- សម្រាប់បេក្ខជនជោគជ័យ៖<br>○ ផ្តល់ឋានៈវិជ្ជាជីវៈ<br>○ ដំឡើងបៀវត្សរ៍<br>○ ផ្តល់កញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ថែម។<br>- សម្រាប់បេក្ខជនមិនទាន់ជោគជ័យ៖<br>○ ទទួលដំណឹងពីចំណុចដែលត្រូវកែលម្អ និងអនុសាសន៍ទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈបន្ថែម<br>○ ត្រូវរង់ចាំរយៈពេលយ៉ាងតិច ១ ឆ្នាំ ទើបមានសិទ្ធិអាចដាក់ពាក្យស្នើសុំទទួលការវាយតម្លៃជាថ្មី។ | ខែកុម្ភៈ | |
| | - កត់ត្រាលទ្ធផលផ្លូវការវាយតម្លៃចូលក្នុងប្រព័ន្ធ HRMIS។ | ខែកុម្ភៈ | |

❖ តារាងសង្ខេបនៃដំណើរវាយតម្លៃទាំងពីរកម្រិត៖

| កម្រិត | ដំណើរការ | សកម្មភាព | អ្នកទទួលខុសត្រូវ | ឧបករណ៍ | ពេលវេលា |
|---|---|---|---|---|---|
| កម្រិតអង្គភាព ឬ គ្រឹះស្ថានសិក្សា | ការរៀបចំផែនការ | - រៀបចំកិច្ចប្រជុំជាមួយបុគ្គលិកទាំងអស់ ដើម្បីកំណត់អ្នកវាយតម្លៃសម្រាប់គ្រូបង្រៀននីមួយៗ នាដើមឆ្នាំសិក្សា។ | - គណៈកម្មការវាយតម្លៃកម្រិតអង្គភាព | - គ្មាន | - ខែវិច្ឆិកា នៃឆ្នាំសិក្សាថ្មី |
| | | - រៀបចំកិច្ចព្រមព្រៀងការងាររបស់ខ្លួន ដែលមានផែនការការងារ□ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំ ព្រមទាំងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាស់ភាពជោគជ័យ។ | - បុគ្គលិក និងអ្នកគ្រប់គ្រងផ្ទាល់រៀងៗខ្លួន | - ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| | | - ផ្ដល់អនុលោមភាពលើកិច្ចព្រមព្រៀងការងាររបស់បុគ្គលិកម្នាក់ៗ | - ប្រធានគណៈកម្មការវាយតម្លៃកម្រិតអង្គភាពនីមួយៗ | - ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ ដែលបានបំពេញរួចរាល់ | |
| | ការប្រឹក្សាយោបល់ តម្រង់ទិស និងគាំទ្រការអភិវឌ្ឍអាជីព | - ពិនិត្យវឌ្ឍនភាពការងារពាក់កណ្ដាលឆ្នាំរបស់បុគ្គលិកដែលខ្លួនទទួលបន្ទុកវាយតម្លៃ ធៀបទៅនឹងផែនការដែលបានដាក់ចេញនៅក្នុងកិច្ចព្រមព្រៀងប្រចាំឆ្នាំ។ | - អ្នកគ្រប់គ្រងផ្ទាល់ និងបុគ្គលិកនីមួយៗ | - ទម្រង់វាយតម្លៃពាក់កណ្ដាលឆ្នាំ | - ខែមីនា |
| | | - ប្រឹក្សាយោបល់ តម្រង់ទិស និងផ្ដល់ការគាំទ្រទាន់ពេលវេលា ដើម្បីសម្រេចផែនការការងារ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដែលបានគ្រោងទុក។ | | | |
| | ការវាយតម្លៃ | - សង្កេតការបង្រៀនរបស់គ្រូដែលខ្លួនត្រូវវាយតម្លៃ។ ការសង្កេតថ្នាក់រៀននេះ ត្រូវធ្វើឡើងជាមួយនឹងយន្តការអធិការកិច្ចផ្ទៃក្នុងរបស់សាលារៀន។ *(សម្រាប់តែគន្លងបង្រៀន)* | - គណៈកម្មការវាយតម្លៃកម្រិតអង្គភាព | - ឧបករណ៍ដែលមានស្រាប់នៅក្នុងយន្តការអធិការកិច្ចផ្ទៃក្នុង | - ខែឧសភា ឬពេលវេលាសមស្របណាមួយនៅក្នុងឆ្នាំសិក្សាមុនពេលវាយតម្លៃចុងឆ្នាំ |
| | | - ធ្វើស្វ័យវាយតម្លៃ ដោយផ្អែកលើសមិទ្ធផលការងារ និងការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រឆ្នាំ។ | - បុគ្គលិកនីមួយៗ | - ទម្រង់ស្វ័យវាយតម្លៃ | - ខែសីហា |
| | | - ប្រមូលព័ត៌មាន៣៦០ដឺក្រេ ពីអ្នកជុំវិញចំនួនបីនាក់ អំពីចរិតលក្ខណៈ និងក្រមសីលធម៌ របស់គ្រូបង្រៀន ដែលត្រូវវាយតម្លៃនោះ។ ការផ្ដល់ព័ត៌មាននេះ ត្រូវធ្វើឡើងដោយសម្ងាត់។ | - អ្នកគ្រប់គ្រងផ្ទាល់នៅកម្រិតអង្គភាពនីមួយៗ | - ទម្រង់ប្រមូលព័ត៌មាន ៣៦០ ដឺក្រេ | |
| | | - វាយតម្លៃលើការអនុវត្តកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់បុគ្គលិក ដោយផ្អែកលើសមិទ្ធផលការងារ ការអភិវឌ្ឍវិជ្ជាជីវៈដែលសម្រេចបានធៀបនឹងផែនការដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងការងារប្រឆ្នាំ លទ្ធផលនៃការវាយម្លៃខ្លួនឯងរបស់បុគ្គលិកនោះ និងព័ត៌មាន៣៦០ដឺក្រេ។ | - អ្នកគ្រប់គ្រងផ្ទាល់នៅកម្រិតអង្គភាពនីមួយៗ | - ទម្រង់វាយតម្លៃការងារចុងឆ្នាំ | |
| | | - ផ្ដល់ការប្រឹក្សាលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការដាក់ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន។ | | | |
| | | - ពិនិត្យ និងអនុម័តលើលទ្ធផលវាយតម្លៃប្រចាំឆ្នាំរបស់បុគ្គលិកម្នាក់ៗ។ | - គណៈកម្មការវាយតម្លៃកម្រិតអង្គភាពនីមួយៗ | - ទម្រង់វាយតម្លៃការងារចុងឆ្នាំ | - ខែកញ្ញា |
| | | - បញ្ជូនលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំទៅតាមឋានានុក្រម។ | | | |
| | ការដាក់ពាក្យសុំទទួលការវាយតម្លៃចូលគន្លងអាជីព | - បំពេញពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីពតាមរយៈគណៈកម្មការវាយតម្លៃកម្រិតអង្គភាព | - បុគ្គលិក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | - ពាក្យស្នើសុំទទួលការវាយតម្លៃចូលគន្លងអាជីព | - ខែតុលា |
| | | - បញ្ជូនពាក្យទៅគណៈកម្មការថ្នាក់ជាតិតាមឋានានុក្រមៈ | - អង្គភាពសាមី | - គ្មាន | |

| | | | | | |
|---|---|---|---|---|---|
| | | ○ ថ្នាក់ក្រោមជាតិ៖ ធ្វើតាមរយៈមន្ទីរ<br>○ ថ្នាក់ជាតិ៖ តាមរយៈអង្គភាពសាមី | | | |
| | | - ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបញ្ជីខ្លី | - មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឬអង្គភាពសាមី | | |
| | | - ផ្ញើបញ្ជីខ្លីទៅគណៈកម្មការថ្នាក់ជាតិ | | | |
| កម្រិតជាតិ | ការពិនិត្យ និងសម្រេចលើបញ្ជីបេក្ខភាព | - ទាញយករបាយការណ៍ពាក់ព័ន្ធនឹងបេក្ខជនដែលត្រូវវាយតម្លៃពី HRMIS | - ការិយាល័យ CPDM | - HRMIS | - ខែវិច្ឆិកាឆ្នាំសិក្សបន្ទាប់ |
| | | - ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខភាពដែលបានស្នើឡើងតាមរយៈមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឬអង្គភាព សាមី ដោយផ្អែកលើរបាយការណ៍ពី HRMIS។ | - គណៈកម្មការវាយតម្លៃកម្រិតជាតិ | - គ្មាន | |
| | ការផ្ទៀងផ្ទាត់ និងវាយតម្លៃ | - រៀបចំផែនការ និងជូនដំណឹងដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឬអង្គភាពសាមី ពីកាលបរិច្ឆេទចុះទៅផ្ទៀងផ្ទាត់ និងវាយតម្លៃដល់អង្គភាព | - ការិយាល័យ CPDM | - គ្មាន | - ខែវិច្ឆិកា |
| | | - ផ្ទៀងផ្ទាត់ និងវាយតម្លៃដល់អង្គភាពដោយផ្តោតលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់<br>- សម្គាល់៖<br>○ បេក្ខជន ត្រូវផ្តល់បទបង្ហាញខ្លីៗអំពីប្រវត្តិការងាររបស់ខ្លួន និងហេតុផលដែលបង្ហាញថាខ្លួនបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យ និងឯកសារភស្តុតាងពាក់ព័ន្ធ។<br>○ សមាជិកគណៈកម្មការវាយតម្លៃកម្រិតជាតិ មានតួនាទីសួរសំណួរទៅបេក្ខជនផ្អែកលើបទបង្ហាញខាងលើរបាយការណ៍ HRMIS និង ឯកសារភស្តុតាងពាក់ព័ន្ធ។<br>- បេក្ខជន មានតួនាទីឆ្លើយតបនឹងសំណួរផ្សេងៗ និងបង្ហាញភស្តុតាងឱ្យបានក្បោះក្បាយ។ | - គណៈកម្មការវាយតម្លៃកម្រិតជាតិ | - លក្ខណៈវិនិច្ឆ័យសម្រាប់គន្លងអាជីពគ្រូបង្រៀន | - ខែធ្នូ |
| | | - ពិនិត្យ ផ្ទៀតផ្ទាត់ និងដាក់ពិន្ទុតាមលក្ខណៈវិនិច្ឆ័យ និងលក្ខណៈវិនិច្ឆ័យរងនីមួយៗ ដូចខាងក្រោម៖<br>○ សម្រាប់គន្លងបង្រៀន និងគន្លងគ្រប់គ្រង៖ ***គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ លទ្ធផលសិក្សារបស់សិស្ស*** និង ***សមត្ថភាពវិជ្ជាជីវៈ***<br>○ សម្រាប់គន្លងឯកទេសអប់រំ៖ ***គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ*** និង ***សមត្ថភាពវិជ្ជាជីវៈ***។ | - គណៈកម្មការវាយតម្លៃកម្រិតជាតិ | - ឧបករណ៍វាយតម្លៃគន្លងអាជីពគ្រូបង្រៀនសម្រាប់គន្លងនីមួយៗ | |
| | ការបូកសរុប និងប្រកាសលទ្ធផល | - បូកសរុបពិន្ទុ និងធ្វើចំណាត់ថ្នាក់បេក្ខជនទូទាំងប្រទេស | - គណៈកម្មការវាយតម្លៃកម្រិតជាតិ | - ឧបករណ៍គណនាពិន្ទុ ( Excel File ) | - ខែមករា |
| | | - ពិនិត្យ និងសម្រេចជ្រើសរើសបេក្ខជនដែលត្រូវដំឡើងឋានៈវិជ្ជាជីវៈ | - គណៈកម្មការវាយតម្លៃកម្រិតជាតិ | - គ្មាន | - ខែកុម្ភៈ |
| | | ប្រកាសលទ្ធផលផ្លូវការ<br>- សម្រាប់បេក្ខជនជោគជ័យ៖<br>○ ផ្តល់ឋានៈវិជ្ជាជីវៈ<br>○ ដំឡើងបៀវត្សរ៍ | | | |

| | | | | | |
|---|---|---|---|---|---|
| | | ○ ផ្ដល់កញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ បន្ថែម។<br>- សម្រាប់បេក្ខជនមិនទាន់ជោគជ័យ៖<br>○ ទទួលដំណឹងពីចំណុចដែលត្រូវកែលម្អ និងអនុសាសន៍ទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈបន្ថែម<br>- ត្រូវរង់ចាំរយៈពេលយ៉ាងតិច ១ ឆ្នាំទើបមានសិទ្ធិអាចដាក់ពាក្យស្នើសុំទទួលការវាយតម្លៃជាថ្មី។ | | | |
| | | - កត់ត្រាលទ្ធផលផ្លូវការវាយតម្លៃចូលក្នុងប្រព័ន្ធ HRMIS។ | - ការិយាល័យ CPDM | - HRMIS | - ខែកុម្ភៈ |

## ៤.២. ការដាក់ពិន្ទុ

ពិន្ទុអតិបរមានៅក្នុងការវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀនគឺ៥០០ និងត្រូវបានបែងចែកលម្អិតដូចក្នុងតារាងខាងក្រោម។

សន្ទស្សន៍ពិន្ទុសម្រាប់កម្រិតឋានៈវិជ្ជាជីវៈទាំងបីនៅក្នុងគន្លងនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖

- **ល្អ** ៥/១០
- **ឈានមុខ** ៨/១០
- **ឆ្នើម** ៩.៨/១០

ដូច្នេះ របបពិន្ទុសម្រាប់ឋានៈវិជ្ជាជីវៈទាំង៣នៅក្នុងគន្លងនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖

- **ល្អ** ២៥០ ដល់ ៣៩៩
- **ឈានមុខ** ៤០០ ដល់ ៤៨៩
- **ឆ្នើម** ៤៩០ ដល់ ៥០០

| លក្ខណៈវិនិច្ឆ័យ | គន្លងបង្រៀន | | | | គន្លងគ្រប់គ្រង | | | | គន្លងឯកទេសអប់រំ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទម្ងន់ពិន្ទុ | ចំនួនលក្ខណៈវិនិច្ឆ័យរង | ពិន្ទុលើលក្ខណៈវិនិច្ឆ័យរងនីមួយៗ | ពិន្ទុសរុប | ទម្ងន់ពិន្ទុ | ចំនួនលក្ខណៈវិនិច្ឆ័យរង | ពិន្ទុលើលក្ខណៈវិនិច្ឆ័យរងនីមួយៗ | ពិន្ទុសរុប | ទម្ងន់ពិន្ទុ | ចំនួនលក្ខណៈវិនិច្ឆ័យរង | ពិន្ទុលើលក្ខណៈវិនិច្ឆ័យរងនីមួយៗ | ពិន្ទុសរុប |
| ១. គុណវុឌ្ឍិ | ១៥% | ៣ | ២៥ | ៧៥ | ១៥% | ៣ | ២៥ | ៧៥ | ២០% | ២ | ៥០ | ១០០ |
| ២. បទពិសោធការងារ | ១៨% | ៧ | ១២.៩ | ៩០ | ១៨% | ៣ | ៣០ | ៩០ | ១៥% | ក[1]-៣<br>ក[2]២ | ២៥<br>៣៧.៥ | ៧៥ |
| ៣. ស្នាដៃការងារ | ១៨% | ៣ | ៣០ | ៩០ | ១៨% | ៣ | ៣០ | ៩០ | ៣០% | ៣ | ៥០ | ១៥០ |
| ៤. លទ្ធផលសិក្សារបស់សិស្ស | ១៤% | ២ | ៣៥ | ៧០ | ១៤% | ៣ | ៣៥ | ៧០ | 0% | 0 | 0 | 0 |
| ៥. សមត្ថភាពវិជ្ជាជីវៈ | ៣៥% | ២៥ | ៧ | ១៧៥ | ៣៥% | ១៩ | ៩.២ | ១៧៥ | ៣៥% | ក[3]-៦<br>ក[4]-១១<br>ក[5]-១៧<br>ក[6]-៩<br>ក[7]-៧ | ២៩.២<br>១៥.៩<br>១០.៣<br>១៩.៤<br>២៥ | ១៧៥ |
| **សរុប** | **១00%** | **៤១** | **១១០** | **៥00** | **១00%** | **៣១** | **១២៩** | **៥00** | **១00%** | | | **៥00** |

1 អ្នកឯកទេស និងអភិវឌ្ឍន៍កម្មវិធីសិក្សា

2 អ្នកឯកទេស វាយតម្លៃលទ្ធផលសិក្សា គរុកោសល្យនិងវិក្រឹតការ និងគ្រប់គ្រងរដ្ឋបាលអប់រំ

3 អ្នកឯកទេស គោលនយោបាយ និងផែនការអប់រំ

4 អ្នកឯកទេស អភិវឌ្ឍកម្មវិធីសិក្សា

5 អ្នកឯកទេស វាយតម្លៃលទ្ធផលសិក្សា

6 អ្នកឯកទេស គរុកោសល្យនិងវិក្រឹតការ

7 អ្នកឯកទេស គ្រប់គ្រងរដ្ឋបាលអប់រំ

## ៤.៣. ការកត់ត្រាព័ត៌មាន



## សទ្ទានុក្រម

**ការវាយតម្លៃប្រចាំឆ្នាំ**
សំដៅដល់យន្តការ ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈជាប្រចាំរបស់បុគ្គលិកអប់រំ ទាំងអស់ដែលគ្របដណ្តប់ដោយក្របខណ្ឌគន្លងអាជីពគ្រូបង្រៀននេះ។ ការវាយតម្លៃនេះ ក៏ជាយន្តការដើម្បីគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់បុគ្គលិកអប់រំតាមរយៈការកំណត់នូវចំណុចខ្វះខាត និងស្វែងរកដំណោះស្រាយដើម្បីពង្រឹងសមត្ថភាពឆ្លើយតបទៅនឹងចំណុចខ្វះខាតទាំងនោះ។

**ការវាយតម្លៃគន្លងអាជីព**
សំដៅដល់យន្តការវាយតម្លៃដើម្បីដំឡើងឋានៈវិជ្ជាជីវៈដែលបានចែងនៅក្នុងគន្លងទាំងបីនៃក្របខណ្ឌគន្លងអាជីពគ្រូបង្រៀននេះ។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមរយៈការដាក់ពាក្យស្នើសុំពីបុគ្គលិកផ្ទាល់ បន្ទាប់ពីបានឆ្លងកាត់ការវាយតម្លៃប្រចាំឆ្នាំ និងការប្រឹក្សាយោបល់ពីអ្នកគ្រប់គ្រងផ្ទាល់ទៅលើការបំពេញលក្ខណៈគ្រប់គ្រាន់របស់បុគ្គលិកម្នាក់។ ការវាយតម្លៃក្នុងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន នឹងផ្តោតលើសូចនាករស្នូលទាំងប្រាំដែលបានរៀបរាប់ខាងលើរួមមាន គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ លទ្ធផលសិក្សារបស់សិស្ស និងសមត្ថភាពវិជ្ជាជីវៈ។

**ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ**
សំដៅដល់វគ្គបំប៉នបច្ចេកទេសនានាជាការអប់រំផ្លូវការ ការសិក្សាវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ដើម្បីជួយ គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវវិជ្ជាសម្បទា បំណិនសម្បទា សមត្ថភាពវិជ្ជាជីវៈ ប្រកបដោយប្រសិទ្ធភាព។

**កាលិកបត្រ**
សំដៅដល់សារព័ត៌មាន ទស្សនាវដ្តី ឬសៀវភៅដែលផ្សាយចេញតាមកាលកំណត់ទៀងទាត់។ នៅក្នុងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន កាលិកបត្រ សំដៅដល់លទ្ធផល ឬស្នាដៃនៃការស្រាវជ្រាវរបស់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ដែលត្រូវបានទទួលស្គាល់ និងបោះពុម្ពនៅក្នុងស្ថាប័នបោះពុម្ពសៀវភៅ ឬស្នាដៃ

ស្រាវជ្រាវដែលមានការទទួលស្គាល់ជាផ្លូវការជាក់លាក់ណាមួយ។ កាលិកបត្រ មានពីរកម្រិត គឺជាតិ និងអន្តរជាតិ។

**ការស្រាវជ្រាវ** សំដៅដល់ការអង្កេតដែលមានលក្ខណៈជាប្រព័ន្ធ លើបញ្ហាណាមួយ ដើម្បីរកដំណោះស្រាយប្រកបដោយវិទ្យាសាស្ត្រ។ ការស្រាវជ្រាវអាចស្ថិតក្នុងកម្រិតផ្សេងៗ ដូចជាកម្រិតថ្នាក់រៀនដែលហៅថាការស្រាវជ្រាវប្រតិបត្តិប្រើសម្រាប់ ដោះស្រាយបញ្ហាសិស្សរៀនខ្សោយកម្រិតសាលារៀន ឬការស្រាវជ្រាវកម្រិតខ្ពស់សម្រាប់បង្កើតទ្រឹស្តីឬវិធីសាស្ត្រអ្វីមួយ។

**គន្លងអាជីពគ្រូបង្រៀន** សំដៅដល់ក្របខណ្ឌសម្រាប់គាំទ្រ និងលើកទឹកចិត្តគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យបំពេញការងារឱ្យអស់ សក្តានុពលរបស់ខ្លួន ដើម្បីធានាឱ្យសិស្សទទួលបានគុណសម្បទាតាមភូមិសិក្សានីមួយៗ ដូចមានចែងក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

**គណៈគ្រប់គ្រងសាលារៀន** សំដៅដល់សមាសភាពថ្នាក់ដឹកនាំនៅតាមសាលារៀនដែលមាននាយក និងនាយករង។

**គុណវុឌ្ឍិ** សំដៅដល់បណ្តុំសមត្ថភាព ទទួលស្គាល់ជាផ្លូវការក្នុងក្របខណ្ឌអប់រំ ឬវិជ្ជាជីវៈដែលបញ្ជាក់ដោយសញ្ញាបត្រ ឬវិញ្ញាបនបត្រ។

**គុណសម្បទា** កញ្ចប់សមត្ថភាពដែលគ្រូបង្រៀន ឬគណៈគ្រប់គ្រងសាលារៀន ឬអ្នកឯកទេសអប់រំ ត្រូវមានសម្រាប់ធានាប្រសិទ្ធភាពនៃការបង្រៀន និងការដឹកនាំដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុករបស់សិស្ស។ គុណសម្បទាក៏ជាកញ្ចប់សមត្ថភាព ដែលសិស្សត្រូវទទួលបានក្រោយពេលបញ្ចប់ភូមិសិក្សានីមួយៗដែលរួមមាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយា សម្បទា។

**គ្រូបង្រៀន** សំដៅដល់គ្រូកម្រិតបឋម គ្រូកម្រិតមធ្យមសិក្សា និងគ្រូកម្រិតឧត្តមនៅក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡាដែលឆ្លងកាត់ពីគ្រូកម្មសិក្សា

ដល់គ្រូតាំងស៊ប់។ គ្រូបង្រៀន គឺជាឋានៈវិជ្ជាជីវៈដំបូង និងមិនទាន់ត្រូវបានវាយតម្លៃដំឡើងឋានៈវិជ្ជាជីវៈជាគ្រូល្អ នាយកល្អ ឬអ្នកឯកទេសអប់រំល្អ និងខ្ពស់ជាងនេះទេ។

គ្រូកម្មសិក្សា — គ្រូកម្មសិក្សាបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅស្ថាប័នបណ្តុះបណ្តាលគ្រូ និងមានគុណវុឌ្ឍិ ចំណេះដឹង និងជំនាញចាំបាច់សម្រាប់បង្រៀនសិស្ស។ គ្រូកម្មសិក្សាចាប់ផ្តើមអនុវត្តនូវអ្វីដែលបានរៀនពីគ្រឹះស្ថានបណ្តុះបណ្តាលគ្រូដោយផ្សារភ្ជាប់រវាងទ្រឹស្តីទៅនឹងការអនុវត្តផ្ទាល់ដោយមានការជួយគាំទ្រពីគ្រូតាំងស៊ប់ គ្រូល្អ គ្រូឈានមុខ ឬគ្រូឆ្នើម។

គ្រូតាំងស៊ប់ — គ្រូតាំងស៊ប់ ជាគ្រូបង្រៀនដែលត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌក្រសួងអប់រំស្របតាមច្បាប់ជាធរមាន។

ដឹបណ្តុះ — ផ្សព្វផ្សាយតម្លៃចរិយាសម្បទាដើម្បីឱ្យអ្នកដទៃជួយផ្សព្វផ្សាយបន្តក្នុងភាពជាគំរូ។

ឋានៈវិជ្ជាជីវៈ — សំដៅដល់ឋានានុក្រមវិជ្ជាជីវៈនៅក្នុងអាជីពមួយ។ នៅក្នុងអាជីពគ្រូបង្រៀន ឋានៈវិជ្ជាជីវៈត្រូវបានកំណត់ទៅតាមគន្លងបីៈ គ្រូបង្រៀន គណៈគ្រប់គ្រង និងអ្នកឯកទេសអប់រំ។ គន្លងគ្រប់គ្រង និងឯកទេស អប់រំ។ នៅក្នុងគន្លងគ្រូបង្រៀន ឋានៈវិជ្ជាជីវៈត្រូវបានកំណត់ជា ៣កម្រិត រួមមាន ១) គ្រូល្អ ២) គ្រូឈានមុខ និង៣) គ្រូឆ្នើម។ នៅក្នុងគន្លងគណៈគ្រប់គ្រង ឋានៈវិជ្ជាជីវៈ ត្រូវបានកំណត់ជា ៣កម្រិត រួមមាន ១) នាយកល្អ ២) នាយកឈានមុខ និង ៣) នាយកឆ្នើម។ ដោយឡែកនៅក្នុងគន្លងអ្នកឯកទេសអប់រំ ឋានៈវិជ្ជាជីវៈត្រូវបានកំណត់ជា ៣កម្រិត រួមមាន ១) អ្នកឯកទេសអប់រំល្អ ២) អ្នកឯកទេសអប់រំឈានមុខ និង៣) អ្នកឯកទេសអប់រំឆ្នើម។

សហគមន៍សិក្សាវិជ្ជាជីវៈ — ជាសហគមន៍មួយដែលផ្តល់នូវការរៀបចំនិងការគាំទ្រចាំបាច់សម្រាប់ក្រុមគ្រូបង្រៀន គណៈគ្រប់គ្រងសាលា និងអ្នកឯកទេសអប់រំ និងជាអ្នកប្រឹក្សាតាមប្រធានបទ ក្នុងការកំណត់គន្លងអភិវឌ្ឍន៍ផ្ទាល់ខ្លួន និងរៀបចំសកម្មភាពដែលនឹងជំរុញការអភិវឌ្ឍរបស់ពួកគេ។

| | |
|---|---|
| សមត្ថភាព | សំដៅដល់ចំណេះដឹង ជំនាញ និងសីលធម៌ ដែលអាចធ្វើឱ្យមនុស្សម្នាក់ធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព ឬមុខងារដែលបានប្រគល់ជូនក្នុងកម្រិតស្តង់ដាដែលរំពឹងទុក។ |
| អ្នកឯកទេសអប់រំ | សំដៅដល់បុគ្គលិកអប់រំដែលភារកិច្ចស្នូលរបស់គាត់គឺមិនមែនបង្រៀន។ អ្នកឯកទេសអប់រំ មានជំនាញឯកទេសផ្សេងៗ ដូចជា អភិវឌ្ឍន៍កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន គរុកោសល្យ រង្វាយតម្លៃការសិក្សា និងមុខវិជ្ជាឯកទេស។ ភារកិច្ចស្នូលរបស់អ្នកឯកទេសអប់រំ គឺធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស និងគោលនយោបាយអប់រំ តាមរយៈការស្រាវជ្រាវ និងផ្តល់យោបល់ជាសំណោរលើការអនុវត្តកម្មវិធីសិក្សា គរុកោសល្យ វិធីសាស្ត្របង្រៀន ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ទាំងនៅកម្រិតសាលារៀន ស្រុកឬខេត្ត និងជាតិ។ |

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖ ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ

### ទម្រង់កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ

(..............................)

| ឈ្មោះបុគ្គលិក៖ | | | | ឈ្មោះអ្នកគ្រប់គ្រងផ្ទាល់៖ |
|---|---|---|---|---|
| តួនាទី៖ | | | | តួនាទី៖ |
| ផែនការសកម្មភាព និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | លទ្ធផលរំពឹងទុក | ឧបសគ្គ | ពេលវេលាកំណត់ | ការគាំទ្រពីអ្នកគ្រប់គ្រងផ្ទាល់ |
| ១. ផែនការសកម្មភាពការងារ<br><br>- លក្ខណៈវិនិច្ឆ័យទី៣៖ អាចជ្រើសរើសយកលក្ខណៈវិនិច្ឆ័យរងតាមចំនួនដែលអាចសម្រេចបានក្នុងរយៈពេល ១ ឆ្នាំ<br>- លក្ខណៈវិនិច្ឆ័យទី៤៖ ជ្រើសរើសយកលក្ខណៈវិនិច្ឆ័យរងទាំងអស់ (លើកលែងតែគន្លងឯកទេសអប់រំ)<br>- លក្ខណៈវិនិច្ឆ័យទី៥៖ ជ្រើសរើសយកលក្ខណៈវិនិច្ឆ័យរងនៅក្នុង វិជ្ជាសម្បទា និងបំណិនសម្បទា | | | | |

| | | | | |
|---|---|---|---|---|
| ២. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖<br>- ជ្រើសរើសយកលក្ខណៈវិនិច្ឆ័យរង នៅក្នុងលក្ខណៈវិនិច្ឆ័យទី ៥ ទាំងឡាយណាដែលខ្លួនគិតថាត្រូវអភិវឌ្ឍ ក្នុងរយៈពេល ១ ឆ្នាំ | | | | |
| ហត្ថលេខាសាមីខ្លួន៖ | | | កាលបរិច្ឆេទ៖ | |
| ហត្ថលេខាអ្នកវាយតម្លៃ៖ | | | កាលបរិច្ឆេទ៖ | |
| ហត្ថលេខាប្រធានអង្គភាព៖ | | | កាលបរិច្ឆេទ៖ | |

# ទម្រង់ពិនិត្យវឌ្ឍនភាពពាក់កណ្ដាលឆ្នាំ

( ....................................... )

<table>
<tr><td colspan="3">ឈ្មោះបុគ្គលិក៖</td><td colspan="2">ឈ្មោះអ្នកគ្រប់គ្រងផ្ទាល់ ៖</td></tr>
<tr><td colspan="3">តួនាទី៖</td><td colspan="2">តួនាទី៖</td></tr>
<tr><th>ផែនការសកម្មភាព និងការអភិវឌ្ឍវិជ្ជាជីវ:ជាប្រចាំ</th><th>លទ្ធផលសម្រេច</th><th>បញ្ហាប្រឈម</th><th>ផែនការបន្ទាប់</th><th>អនុសាសន៍ពីអ្នកដឹកនាំ</th></tr>
<tr><td>១. ផែនការសកម្មភាពការងារ<br><br>(យកចេញពីកិច្ចព្រមព្រៀងការងារ)</td><td></td><td></td><td></td><td></td></tr>
</table>

| | | | | |
|---|---|---|---|---|
| ២. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖<br><br>(យកចេញពីកិច្ចព្រមព្រៀងការងារ) | | | | |
| ហត្ថលេខាសាមីខ្លួន៖ | | | កាលបរិច្ឆេទ៖ | |
| ហត្ថលេខាអ្នកដឹកនាំផ្ទាល់ ៖ | | | កាលបរិច្ឆេទ៖ | |
| ហត្ថលេខាប្រធានអង្គភាព៖ | | | កាលបរិច្ឆេទ៖ | |

ឧបសម្ព័ន្ធ ៣៖ ឧបករណ៍វាយតម្លៃការងារចុងឆ្នាំ

# ឧបករណ៍វាយតម្លៃការងារចុងឆ្នាំ

(............................................)

<table>
<tr><td colspan="2">ឈ្មោះបុគ្គលិក៖</td><td colspan="3">ឈ្មោះអ្នកគ្រប់គ្រងផ្ទាល់ ៖</td></tr>
<tr><td colspan="2">តួនាទី៖</td><td colspan="3">តួនាទី៖</td></tr>
<tr><th>ផែនការសកម្មភាព និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ</th><th>លទ្ធផលរំពឹងទុក</th><th>លទ្ធផលសម្រេច</th><th>ភស្តុតាង ឬបរិយាយ</th><th>ពិន្ទុ</th></tr>
<tr><td>១. ផែនការសកម្មភាពការងារ<br><br>(យកចេញពីកិច្ចព្រមព្រៀងការងារ)</td><td></td><td></td><td></td><td></td></tr>
<tr><td>២. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖<br><br>(យកចេញពីកិច្ចព្រមព្រៀងការងារ)</td><td></td><td></td><td></td><td></td></tr>
</table>

| | | |
|---|---|---|
| យោបល់សាមីខ្លួន | | |
| យោបល់របស់អ្នកវាយតម្លៃ (វឌ្ឍនភាពទូទៅធៀបនឹងកិច្ចព្រមព្រៀងការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ) | | ពិន្ទុសរុប៖ |
| អនុសាសន៍លើការដាក់ពាក្យឡើងគន្លងអាជីព | បាទ ☐<br>ទេ ☐ | |
| ហត្ថលេខាសាមីខ្លួន | | |
| ហត្ថលេខាអ្នកវាយតម្លៃ | | |
| ហត្ថលេខាប្រធានអង្គភាព | | |

# ឧបករណ៍ស្វ័យវាយតម្លៃការងារប្រចាំឆ្នាំ

(........................................)

| ឈ្មោះបុគ្គលិក៖ | | | | |
|---|---|---|---|---|
| តួនាទី៖ | | | | |
| ផែនការសកម្មភាព និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | លទ្ធផលរំពឹងទុក | លទ្ធផលសម្រេចបាន(ពិន្ទុ) | បរិយាយ ឬឧស្សគ្គតាង | បញ្ហាប្រឈម |
| ១. ផែនការសកម្មភាពការងារ | | | | |
| ពិន្ទុសរុប(១) | | | | |
| ២. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| **ពិន្ទុសរុប(២)** | | | | |
| **ពិន្ទុសរុបប្រចាំឆ្នាំ** (១) + (២) | | | | |
| ហត្ថលេខាសាមីខ្លួន៖ | | | កាលបរិច្ឆេទ៖ | |

## ឧបសម្ព័ន្ធ ៥៖ ឧបករណ៍ប្រមូលព័ត៌មាន ៣៦០ ដឺក្រេ

| | |
|---|---|
| ឈ្មោះបេក្ខជន៖ | តួនាទី៖ |
| ឈ្មោះអ្នកផ្តល់ព័ត៌មាន៖ | តួនាទី៖ |

| ចរិយាសម្បទា | សូមគូសចម្លើយដែលសមស្រប | | | | ផ្សេងៗ |
|---|---|---|---|---|---|
| | មិនយល់ស្រប | យល់ស្រប ខ្លះៗ | យល់ស្រប មធ្យម | យល់ស្រប ខ្លាំង | |
| ការយកចិត្តទុកដាក់ ថែរក្សាសិស្ស និងធ្វើការដើម្បីប្រយោជន៍សិស្ស និងសង្គម | ១ | ២ | ៣ | ៤ | |
| ការប្តេជ្ញាចិត្ត និងរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ | ១ | ២ | ៣ | ៤ | |
| ការប្រតិបត្តិអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងសុខដុម ជាមួយសិស្ស និងសហគមន៍ | ១ | ២ | ៣ | ៤ | |
| ការប្រតិបត្តិដោយភាពយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស សហការី និងសមាជិកផ្សេងទៀតក្នុងសហគមន៍ | ១ | ២ | ៣ | ៤ | |
| យោបល់បន្ថែម៖ | | | | | |

| | |
|---|---|
| ហត្ថលេខាអ្នកផ្តល់ព័ត៌មាន | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**ខេត្តៈ** ............................................
**អង្គភាព ឬគ្រឹះស្ថានសិក្សាៈ**......................................

## ការវាយតម្លៃចូលគន្លងបង្រៀននៃក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ឈ្មោះគ្រូ.............................................គ្រូបង្រៀនកម្រិត.................................អាយុ..................ភេទ ..................មុខវិជ្ជាឯកទេស (សម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ)..................................... បង្រៀនថ្នាក់ទី.....................។

## គណៈកម្មការវាយតម្លៃ

១.................................................................តួនាទី.........................................................................

២.................................................................តួនាទី.........................................................................

៣.................................................................តួនាទី.........................................................................

៤.................................................................តួនាទី.........................................................................

៥.................................................................តួនាទី.........................................................................

៦.................................................................តួនាទី.........................................................................

៧.................................................................តួនាទី.........................................................................

៨.................................................................តួនាទី.........................................................................

៩.................................................................តួនាទី.........................................................................

**កាលបរិច្ឆេទ៖**.....................................................................................................................................

**១ .ឧបករណ៍សម្រាប់វាយតម្លៃ *<u>គ្រូបង្រៀន</u>* ចូលគន្លងបង្រៀននៅក្នុងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន**

| លក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យរង | សូចនាករ | លទ្ធផល | សេចក្តីពន្យល់ ឬភស្តុតាង |
|---|---|---|---|---|
| ១. គុណវុឌ្ឍិ | ១.១. កម្រិតវប្បធម៌ | ១.១.០. មិនមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ | ០ | |
| | | ១.១.១. កម្រិតបរិញ្ញាបត្រ | ១ | |
| | | ១.១.២. កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | ២ | |
| | | ១.១.៣. កម្រិតបណ្ឌិត | ៣ | |
| | ១.២. កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ | ១.២.០. មិនមានសញ្ញាបត្របណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀនណាមួយ ឬសញ្ញាបត្រដែលមានតម្លៃស្មើ | ០ | |
| | | ១.២.១. សញ្ញាបត្របណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀនណាមួយ ឬសញ្ញាបត្រដែលមានតម្លៃស្មើ | ៣ | |
| | ១.៣. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ១.៣.០. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈតិចជាង ៦ ក្រេឌីត | ០ | |
| | | ១.៣.១. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៦ ក្រេឌីត | ១ | |
| | | ១.៣.២. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ៩ ក្រេឌីត | ២ | |
| | | ១.៣.៣. ចូលរួមការអភិវឌ្ឍវិជ្ជាជីវៈបាន ១២ ក្រេឌីត | ៣ | |
| ២. បទពិសោធការងារ | ២.១. បទពិសោធបង្រៀន | ២.១.០. មានបទពិសោធបង្រៀនតិចជាង ៥ ឆ្នាំ | ០ | |
| | | ២ .១.១.មានបទពិសោធបង្រៀន ៥ ឆ្នាំ | ១ | |
| | | ២.១.២. មានបទពិសោធបង្រៀន ៧ ឆ្នាំ | ២ | |
| | | ២.១.៣. មានបទពិសោធបង្រៀន ១០ ឆ្នាំ | ៣ | |
| | ២.២. បទពិសោធដឹកនាំបង្ហាត់កម្មសិក្សាការី (គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬ គ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិត | ២.២.០. មានបទពិសោធដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី (គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬ គ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិតតិចជាង ៣ នាក់ | ០ | |
| | | ២.២.១. ដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី (គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិតបាន ៣ នាក់ | ១ | |
| | | ២.២.២. ដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី(គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិតបាន ៥ នាក់ | ២ | |

| | | | | |
|---|---|---|---|---|
| | | ២.២.៣. ដឹកនាំបង្ហាត់បង្រៀនកម្មសិក្សាការី(គ្រូចេញថ្មី) គ្រូកិច្ចសន្យា ឬគ្រូដែលមានបច្ចេកទេសបង្រៀននៅមានកម្រិតបាន ៧ នាក់ | ៣ | |
| | ២.៣. បទពិសោធជាគ្រូទទួលបន្ទុកថ្នាក់ | ២.៣.០. មិនមានបទពិសោធជាគ្រូទទួលបន្ទុកថ្នាក់ | ០ | |
| | | ២.៣.១. ជាគ្រូទទួលបន្ទុកថ្នាក់បាន ១ ឆ្នាំ | ៣ | |
| | ២.៤. បទពិសោធជាប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា | ២.៤.០. មិនមានបទពិសោធជាប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជា | ០ | |
| | | ២.៤.១. ជាប្រធានក្រុមបច្ចេកទេស ឬប្រធានមុខវិជ្ជាបាន ៣ ឆ្នាំ | ៣ | |
| | ២.៥. មានទពិសោធបង្រៀននៅតាមសាលាក្នុងតំបន់ដាច់ស្រយាល ខ្វះគ្រូ ឬ តំបន់ជួបការលំបាក | ២.៥.០. មានបទពិសោធបង្រៀននៅតាមសាលាក្នុងតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាកតិចជាង ៣ ឆ្នាំ | ០ | |
| | | ២.៥.១. មានបទពិសោធបង្រៀននៅតាមសាលាតាមតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាក ៣ ឆ្នាំ | ១ | |
| | | ២.៥.២. មានបទពិសោធបង្រៀននៅតាមសាលាតាមតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាក ៥ ឆ្នាំ | ២ | |
| | | ២.៥.៣. មានបទពិសោធបង្រៀននៅតាមសាលាតាមតំបន់ដាច់ស្រយាល និងខ្វះគ្រូ ឬ តំបន់ជួបការលំបាក ៧ ឆ្នាំ | ៣ | |
| | ២.៦. បទពិសោធធ្វើអធិការកិច្ចថ្នាក់រៀន | ២.៦.០. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនតិចជាង ៥ ដង | ០ | |
| | | ២.៦.១. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនបាន ៥ ដង | ១ | |
| | | ២.៦.២. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនបាន ៩ ដង | ២ | |
| | | ២.៦.៣. មានបទពិសោធធ្វើអធិការកិច្ចថ្នាក់រៀនបាន ១៤ ដង | ៣ | |
| | ២.៧. សមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន | ២.៧.០. មិនបានចូលរួមជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ | ០ | |
| | | ២.៧.១. ចូលរួមជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ | ១ | |
| | | ២.៧.២. សម្របសម្រួលសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈ | ២ | |
| | | ២.៧.៣. បង្កើតគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងការដឹកនាំសកម្មភាពផ្សេងៗរបស់សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ | ៣ | |
| ៣. ស្នាដៃការងារ | ៣.១. ការបោះពុម្ពស្នាដៃស្រាវជ្រាវប្រតិបត្តិ | ៣.១.០. ចំនួន ១ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ (មិនបានបោះពុម្ព) | ០ | |
| | | ៣.១.១. ចំនួន ១ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ | ១ | |
| | | ៣.១.២. ចំនួន ៣ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ | ២ | |

| | | | | |
|---|---|---|---|---|
| | | ៣.១.៣. ចំនួន ៥ អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវ | ៣ | |
| | ៣.២. ការផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន | ៣.២.០. មិនបានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន | ០ | |
| | | ៣.២.១. បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ១ ស្នាដៃ | ១ | |
| | | ៣.២.២. បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ៣ ស្នាដៃ | ២ | |
| | | ៣.២.៣. បានផលិតឯកសារជំនួយក្នុងការរៀន និងបង្រៀន ៥ ស្នាដៃ | ៣ | |
| | ៣.៣. ការផលិត និងផ្សព្វផ្សាយការបង្រៀនសិស្សតាមប្រព័ន្ធអនឡាញ | ៣.៣.០. មិនបានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញ | ០ | |
| | | ៣.៣.១. បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ១ មេរៀន | ១ | |
| | | ៣.៣.២. បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ៣ មេរៀន | ២ | |
| | | ៣.៣.៣. បានផលិត និងផ្សព្វផ្សាយការបង្រៀនតាមប្រព័ន្ធអនឡាញបាន ៥ មេរៀន | ៣ | |
| | ៣.៤. ការចូលរួម និងចែករំលែកបទពិសោធនៅក្នុងសិក្ខាសាលា សន្និសីទ វគ្គបណ្ដុះបណ្ដាលឬការអញ្ជើញពិសេសណាមួយ | ៣.៤.០. បានចូលរួម និងចែករំលែកបទពិសោធតិចជាង ៣ ដង | ០ | |
| | | ៣.៤.១. ចំនួន ៣ កម្មវិធី | ១ | |
| | | ៣.៤.២. ចំនួន ៥ កម្មវិធី | ២ | |
| | | ៣.៤.៣. ចំនួន ១០ កម្មវិធី | ៣ | |
| | ៣.៥. ស្នាដៃវិជ្ជាជីវៈជាក់លាក់ផ្សេងទៀត | ៣.៥.០. មិនមានស្នាដៃដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬរាជរដ្ឋាភិបាល | ០ | |
| | | ៣.៥.១. មានស្នាដៃដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬរាជរដ្ឋាភិបាល | ៣ | |
| ៤. លទ្ធផលសិក្សារបស់សិស្ស *ករណីលើកលែង៖សម្រាប់មត្តេយ្យសិក្សា លក្ខណៈវិនិច្ឆ័យនេះត្រូវលើកលែង* | ៤.១. ភាគរយសិស្សក្នុងសាលាដែលខ្លួនបង្រៀនប្រឡងជាប់តេស្តស្តង់ដាកើនឡើងធៀប លទ្ធផលដើមឆ្នាំ | ៤.១.០. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្តស្តង់ដាកើនឡើងក្រោម ៣០ ភាគរយធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | ០ | |
| | | ៤.១.១. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្ត ស្តង់ដាកើនឡើងយ៉ាងហោចណាស់ ៣០ ភាគរយធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | ១ | |
| | | ៤.១.២. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និង | ២ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ទុតិយភូមិ ប្រឡងជាប់តេស្ត ស្តង់ដាកើនឡើងយ៉ាងហោចណាស់ពី ៥០ ភាគរយ ដល់ក្រោម ៧០ ភាគរយ ធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | | |
| | | | | ៤.១.៣. ភាគរយសិស្សក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូនៅបឋមសិក្សា ឬលើមុខវិជ្ជាក្នុងថ្នាក់ដែលខ្លួនបង្រៀនសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ប្រឡងជាប់តេស្ត ស្តង់ដាកើនឡើងយ៉ាងហោចណាស់ពី ៧០ ភាគរយឡើងទៅធៀបនឹងលទ្ធផលតេស្តដើមឆ្នាំ | ៣ | |
| | | | ៤.២. អត្រាសិស្សបោះបង់ | ៤.២.១. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀនៈ<br>- សម្រាប់បឋមសិក្សា លើសពី ២ ភាគរយ<br>- សម្រាប់មធ្យមសិក្សា លើលពី ៩ ភាគរយ | ០ | |
| | | | | ៤.២.១. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀនៈ<br>- សម្រាប់បឋមសិក្សា យ៉ាងច្រើនណាស់ ២ ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៩ ភាគរយ | ១ | |
| | | | | ៤.២.២. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀនៈ<br>- សម្រាប់បឋមសិក្សា យ៉ាងច្រើនណាស់ ១ ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៦ ភាគរយ | ២ | |
| | | | | ៤.២.៣. អត្រាសិស្សបោះបង់ក្នុងថ្នាក់ដែលខ្លួនបង្រៀនៈ<br>- សម្រាប់បឋមសិក្សា ០ ភាគរយ<br>- សម្រាប់មធ្យមសិក្សា យ៉ាងច្រើនណាស់ ៣ ភាគរយ | ៣ | |
| ៥. សមត្ថភាពវិជ្ជាជីវៈ | ៥.១. វិជ្ជាសម្បទា | ចំណេះដឹងអំពីសិស្ស | ៥.១.១. ការយល់ដឹងអំពីសិស្សៈ ប្រភេទសិស្សតម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះ ឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងដឹងពីរបៀបដោះស្រាយ | ៥.១.១.០ មិនអាចពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះ ឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ០ | |
| | | | | ៥.១.១.១. ពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ១ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ៥.១.១.២. សម្របសម្រួល សហការ និងគាំទ្រសហការី ឱ្យពណ៌នាបានពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ២ | |
| | | | | ៥.១.១.៣. ពណ៌នាបានពីគោលវិធី ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីប្រភេទសិស្ស តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា ឥរិយាបថ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងរបៀបដោះស្រាយ | ៣ | |
| | | ចំណេះដឹងអំពីខ្លឹមសារមេរៀន | ៥.១.២. ការយល់ដឹងគោលនយោបាយអប់រំ គោលដៅអប់រំ គោលបំណងអប់រំចំណេះទូទៅ និងកម្មវិធីសិក្សា | ៥.១.២.០. មិនអាចពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ០ | |
| | | | | ៥.១.២.១. ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ១ | |
| | | | | ៥.១.២.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ២ | |
| | | | | ៥.១.២.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ កម្មវិធីសិក្សា ព្រមទាំងយុទ្ធសាស្ត្រដែលធ្វើឱ្យសម្រេចគោលដៅទាំងនោះ | ៣ | |
| | | | ៥.១.៣. ការយល់ដឹងអំពីការរៀបចំ ផែនការ និងកិច្ចតែងការបង្រៀន | ៥.១.៣.០. មិនអាចប្រាប់បានពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន ជាដើម | ០ | |
| | | | | ៥.១.៣.១. ប្រាប់បានពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន ជាដើម | ១ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ៥.១.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាពីរបៀបរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន | ២ | |
| | | | | ៥.១.៣.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ដើម្បីលើកកម្ពស់ការយល់ដឹងពីការរៀបចំផែនការ និងកិច្ចតែងការបង្រៀនបានច្បាស់លាស់ ដោយបញ្ជាក់ពីវត្ថុបំណង វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងសម្ភាររៀន និងបង្រៀន។ | ៣ | |
| | | | ៥.១.៤. ការយល់ដឹងអំពីខ្លឹមសារកម្មវិធីសិក្សា | ៥.១.៤.០. មិនអាចពន្យល់បានអំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ០ | |
| | | | | ៥.១.៤.១. ពន្យល់បានអំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ១ | |
| | | | | ៥.១.៤.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យយល់ច្បាស់អំពីខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ២ | |
| | | | | ៥.១.៤.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពី ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សា និងរបៀបនៃការបង្រៀននូវខ្លឹមសារទាំងនោះទៅដល់សិស្ស | ៣ | |
| | | | ៥.១.៥. ការយល់ដឹងអំពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត | ៥.១.៥.០. មិនអាចពណ៌នាបានពីវិធីសាស្ត្រសម្បូរបែបក្នុងការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ០ | |
| | | | | ៥.១.៥.១. ពណ៌នាបានពីវិធីសាស្ត្រសម្បូរបែបក្នុងការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ១ | |
| | | | | ៥.១.៥.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីវិធីសាស្ត្រសម្បូរបែបសម្រាប់ បញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ២ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ៥.១.៥.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីវិធីសាស្ត្រសម្បូរបែបសម្រាប់ បញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងៗ ដែលអាចជួយឱ្យសិស្សរៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន | ៣ | |
| | | ចំណេះដឹងអំពីរបៀបរៀនរបស់សិស្ស | ៥.១.៦. ការយល់ដឹងអំពីបរិស្ថានសិក្សាក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ | ៥.១.៦.០. មិនអាចពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ០ | |
| | | | | ៥.១.៦.១. ពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ១ | |
| | | | | ៥.១.៦.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីវិធីដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ២ | |
| | | | | ៥.១.៦.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពី វិធីសាស្ត្រដែលធ្វើឱ្យបរិស្ថានក្នុងថ្នាក់រៀន និងការចូលរួមរបស់សហគមន៍ប្រសើរឡើង | ៣ | |
| | | | ៥.១.៧. ការយល់ដឹងអំពីរបៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | ៥.១.៧.០. មិនអាចពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | ០ | |
| | | | | ៥.១.៧.១. ពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | ១ | |
| | | | | ៥.១.៧.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យពណ៌នាបានពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យ និងល្បឿនសិក្សារបស់សិស្ស | ២ | |
| | | | | ៥.១.៧.៣. ពណ៌នាបានពីគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ដើម្បីលើកកម្ពស់ការយល់ដឹងពីទ្រឹស្តីផ្សេងៗ របៀបរៀន ទេពកោសល្យនិងល្បឿនសិក្សារបស់សិស្ស | ៣ | |
| | ៥.២. បំណិន សម្បទា | ការធ្វើផែនការ និងការពិនិត្យ | ៥.២.១. ការអនុវត្តផែនការបង្រៀន កិច្ចតែងការបង្រៀនដោយបញ្ជាក់អំពីលទ្ធផលសិក្សារំពឹងទុកស្របតាមសមត្ថភាពសិស្ស និងការវាយ | ៥.២.១.០. មិនបានរៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀនច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ០ | |
| | | | | ៥.២.១.១. រៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀនច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ១ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | តម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព | ៥.២.១.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យរៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀនច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ២ | |
| | | | | ៥.២.១.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ការរៀបចំផែនការបង្រៀន និង កិច្ចតែងការបង្រៀន ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍កំណត់ | ៣ | |
| | | | ៥.២.២. ការរៀបចំសម្ភារៈរៀន និងបង្រៀនដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ | ៥.២.២.០. មិនបានរៀបចំសម្ភារៈរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ០ | |
| | | | | ៥.២.២.១. រៀបចំសម្ភារៈរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ១ | |
| | | | | ៥.២.២.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យរៀបចំសម្ភារៈរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ២ | |
| | | | | ៥.២.២.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ដើម្បីរៀបចំសម្ភារៈរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | ៣ | |
| | | | ៥.២.៣. ការប្រើវិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ៥.២.៣.០. មិនបានប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ០ | |
| | | | | ៥.២.៣.១. ប្រើប្រាស់វិធីសាស្ត្រសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ១ | |
| | | | | ៥.២.៣.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ២ | |
| | | | | ៥.២.៣.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ប្រើប្រាស់វិធីសាស្ត្រសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ៣ | |
| | | | ៥.២.៤. ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃលទ្ធផលសិក្សា សម្រាប់ការកែលម្អដំណើរការរៀន និងបង្រៀន និងលើកកម្ពស់គុណផលសិក្សា | ៥.២.៤.០. មិនបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃការសិក្សា ដើម្បីកែលម្អការរៀន និងបង្រៀន ព្រមទាំងលើកកម្ពស់លទ្ធផលសិក្សា | ០ | |
| | | | | ៥.២.៤.១. ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃការសិក្សា ដើម្បីកែលម្អការរៀន និងបង្រៀន ព្រមទាំងលើកកម្ពស់លទ្ធផលសិក្សា | ១ | |
| | | | | ៥.២.៤.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យប្រើប្រាស់លទ្ធផលនៃការវាយតម្លៃការសិក្សា ដើម្បីកែលម្អការរៀន និងបង្រៀន ព្រមទាំងលើកកម្ពស់លទ្ធផលសិក្សា | ២ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ៥.២.៤.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃការសិក្សា ដើម្បីកែលម្អការរៀន និងបង្រៀន ព្រមទាំងលើកកម្ពស់លទ្ធផលសិក្សា | ៣ | |
| | | | ៥.២.៥. ការតាមដានការចូលរួម និងថែរក្សាកំណត់ត្រាស្នាដៃនៃភាពរីកចម្រើនរបស់សិស្ស | ៥.២.៥.០. មិនបានតាមដានការចូលរួមរបស់សិស្ស | ០ | |
| | | | | ៥.២.៥.១. តាមដានការចូលរួមរបស់សិស្ស | ១ | |
| | | | | ៥.២.៥.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យតាមដានការចូលរួមរបស់សិស្ស | ២ | |
| | | | | ៥.២.៥.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីតាមដានការចូលរួមរបស់សិស្ស | ៣ | |
| | | | ៥.២.៦. ការផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថ | ៥.២.៦.០. មិនបានផ្តល់ពត៌មានត្រឡប់ទៅសិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលសិស្ស | ០ | |
| | | | | ៥.២.៦.១. ផ្តល់ពត៌មានត្រឡប់ទៅសិស្ស និងមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស | ១ | |
| | | | | ៥.២.៦.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យផ្តល់ពត៌មានត្រឡប់ទៅសិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្ស | ២ | |
| | | | | ៥.២.៦.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីផ្តល់ពត៌មានត្រឡប់ទៅសិស្ស និងមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស | ៣ | |
| | | ការគ្រប់គ្រងបរិស្ថានសិក្សា | ៥.២.៧. ការបង្កើតបរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព | ៥.២.៧.០. មិនបានបង្កើតបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យសិស្សខិតខំរៀនសូត្រអស់ពីលទ្ធភាព | ០ | |
| | | | | ៥.២.៧.១. បង្កើតបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យសិស្សខិតខំរៀនសូត្រអស់ពីលទ្ធភាព | ១ | |
| | | | | ៥.២.៧.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យបង្កើត បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យសិស្សខិតខំរៀនសូត្រអស់ពីលទ្ធភាព | ២ | |
| | | | | ៥.២.៧.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីបង្កើតបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យសិស្សខិតខំរៀនសូត្រអស់ពីលទ្ធភាព។ | ៣ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ៥.២.៨. ការជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន | ៥.២.៨.០. មិនបានជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន | ០ | |
| | | | | ៥.២.៨.១. ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន | ១ | |
| | | | | ៥.២.៨.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន | ២ | |
| | | | | ៥.២.៨.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ | ៣ | |
| | | | ៥.២.៩. ការចូលរួមអភិវឌ្ឍសាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាព របស់សិស្ស ព្រមទាំងសហការី | ៥.២.៩.០. មិនបានចូលរួមអភិវឌ្ឍសាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហការី | ០ | |
| | | | | ៥.២.៩.១. ចូលរួមអភិវឌ្ឍសាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហការី | ១ | |
| | | | | ៥.២.៩.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យចូលរួមអភិវឌ្ឍសាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហការី | ២ | |
| | | | | ៥.២.៩.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីចូលរួមអភិវឌ្ឍសាលារៀន ក្នុងគោលបំណងទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហការី | ៣ | |
| | | ការប្រើប្រាស់វិធីបង្រៀន | ៥.២.១០. ការប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង | ៥.២.១០.០. មិនបានប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង | ០ | |
| | | | | ៥.២.១០.១. ប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង | ១ | |
| | | | | ៥.២.១០.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង | ២ | |
| | | | | ៥.២.១០.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីប្រើប្រាស់វិធីបង្រៀនផ្សេងៗ ក្នុងគោលបំណងជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង | ៣ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ៥.២.១១. ការកំណត់សកម្មភាពបង្រៀនស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា សមត្ថភាព និងប្រភេទសិស្ស | ៥.២.១១.០. កំណត់សកម្មភាពបង្រៀនមិនស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា សមត្ថភាព និងប្រភេទសិស្ស | ០ | |
| | | | | ៥.២.១១.១. កំណត់សកម្មភាពបង្រៀនស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា សមត្ថភាព និងប្រភេទសិស្ស | ១ | |
| | | | | ៥.២.១២.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យកំណត់សកម្មភាពបង្រៀនស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា សមត្ថភាព និងប្រភេទសិស្ស | ២ | |
| | | | | ៥.២.១២.៣. បង្កើតគោលវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីកំណត់សកម្មភាពបង្រៀនស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា សមត្ថភាព និងប្រភេទសិស្ស។ | ៣ | |
| | | | ៥.២.១២. ការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីធ្វើឱ្យការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព | ៥.២.១២.០. មិនបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីធ្វើឱ្យការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព | ០ | |
| | | | | ៥.២.១២.១. ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីធ្វើឱ្យការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព | ១ | |
| | | | | ៥.២.១២.២. សម្របសម្រួល សហការ និងគាំទ្រសហការីឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីធ្វើឱ្យការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព | ២ | |
